# បៀតបៀនដល់កេរ្តិ៍ខ្មាស់

ខែ មិនា ២០០៤

ព័ត៌មានបន្ថែម សូមទំនាក់ទំនងៈ

**វេជ្ជ. ពុង ឈីវកេក**

**ប្រធានអង្គការលីកាដូ**

**អាសយដ្ឋានលេខ១៦ ផ្លូវ៩៩ ភ្នំពេញ កម្ពុជា**

ប្រអប់សំបុត្រលេខ : ៤៩៩ ប្រៃសណីយ៍ភ្នំពេញ

ទូរស័ព្ទលេខ :(៨៥៥) ២៣ ៣៣០ ៩៦៥ / ៣៦៤ ៩០១

**ទូរសារលេខ :(៨៥៥) ២៣ ៣៣០ ៩៦៥ / ២១៧ ៦២៦**

អ៊ីម៉ែលៈlicadho@camnet.com.kh

គេហទំព័រៈ http://www.licadho.org/

# បុព្វកថា

អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (លីកាដូ)[១] មានសេចក្តីរីករាយដើម្បីនឹងបង្ហាញនូវរបាយការណ៍សង្ខេបដែលឆ្លុះបញ្ចាំងជាទូទៅអំពីការអនុវត្តន៍លើករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ទាំងឡាយនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ក្នុងឆ្នាំ ២០០២ និង២០០៣[២] កន្លងទៅនេះ ។ របាយការណ៍ដែលលំអិត និងមានការវិភាគល្អិនល្អន់ជាងនេះស្តីអំពីប្រធានបទរៀបរាប់គ្រប់ដណ្តប់ក្នុងអំឡុងដូចគ្នានឹងចេញផ្សាយនៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៤ ខាងមុខនេះ ដើម្បីជួយតុលាការ និងមន្ត្រីអនុវត្តច្បាប់នានាក្នុងការដោះស្រាយភាពស្មុគស្មាញលើផ្នែកច្បាប់ដែលពាក់ព័ន្ធនឹងករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់នេះ[៣] ។

ចាប់ពីថ្ងៃទី ១ ខែ មករា រហូតមកដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០២ កន្លងមកអង្គការ លីកាដូបានទទួល និងស៊ើបអង្កេតលើពាក្យបណ្តឹងករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ចំនួន ១៧៩ ករណី ។ ក្នុងករណីទាំងនោះមាន ៥៨ករណីបានផ្តន្ទាទោស ក្នុងចំណោមនោះជាលទ្ធផលមាន ៥៦ករណីត្រូវបានផ្តន្ទាទោសទោស[៤] ដាក់ពន្ធនាគារ និង ២ករណីទៀតត្រូវបានវិនិច្ឆ័យអោយរួចទោស ។ បើគិតអំឡុងរយៈពេលដូចគ្នានេះ ក្នុងឆ្នាំ ២០០៣ កន្លងមកអង្គការលីកាដូបានទទួល និងស៊ើបអង្កេតលើករណីបណ្តឹងចំនួន ១៧៧ករណី ។ ការវិនិច្ឆ័យទោសចំនួនតែ ៥ករណីជាលទ្ធផល ៤ករណីត្រូវបានវិនិច្ឆ័យទោសអោយជាប់ពន្ធនាគារ និង ១ករណីទៀតកាត់អោយរួចទោស ។ លើសពីនេះទៅទៀត លីកាដូបានធ្វើការត្រួតពិនិត្យទៅលើ ២២១ករណី ផ្សេងទៀតដែលត្រូវបានផ្សាយតាមកាសែតក្នុងស្រុកក្នុងឆ្នាំ ២០០២ និង ២២៦ករណីក្នុងឆ្នាំ ២០០៣ ។ ប៉ុន្តែរាល់ករណីទាំងអស់ដែលចុះផ្សាយតាមកាសែតក៏មានខ្លះមិនត្រូវបានស៊ើបអង្កេតដោយអង្គការលីកាដូទេ ។

អង្គការលីកាដូសូមស្វាគមន៍ ចំពោះការផ្តន្ទាទោសរាល់ករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ទាំងឡាយ ប៉ុន្តែអង្គការក៏នៅតែមានកង្វល់យ៉ាងខ្លាំង ចំពោះការអនុវត្តន៍តាមនិតិវិធីច្បាប់ចំពោះករណីព្រហ្មទណ្ឌប្រភេទនេះនៅក្នុងលំដាប់គ្រប់ប្រព័ន្ធតុលាការទាំងអស់ ។ លីកាដូមានការខ្វាយខ្វល់ជាពិសេស អំពីការបកស្រាយច្បាប់មួយចំនួនដោយប្រព័ន្ធតុលាការ និងភាពទន់ខ្សោយក្នុងការស៊ើបអង្កេតដែលប៉ះពាល់ដល់ការផ្តន្ទាទោស ក៏ដូចជាការដោះ

---

[១] លីកាដូ គឺជាអង្គការមិនមែនរដ្ឋាភិបាល និងមិនធ្វើនយោបាយ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩១។ ទីស្នាក់ការកណ្តាលនៅភ្នំពេញត្រូវបានបើកនៅខែ កក្កដា ឆ្នាំ១៩៩២ ។ កម្មវិធីរបស់អង្គការលីកាដូរួមមាន: ការឃ្លាំមើលអំពើហឹង្សាផ្នែកនយោបាយ អប់រំសិទ្ធិមនុស្ស ផ្តល់ជំនួយផ្នែកសុវាសុខភាព កម្មវិធីប្រឆាំងអំពើនឹងទារុណកម្ម កម្មវិធីសិទ្ធិកុមារ សិទ្ធិស្ត្រី និងការស្វែងរកការគាំទ្រមតិ ។ បច្ចុប្បន្ន លីកាដូមានការិយាល័យតាមបណ្តាខេត្តចំនួន ១២ និងការិយាកណ្តាលនៅភ្នំពេញ។

[២] របាយការណ៍នេះបានដកស្រង់យ៉ាងច្រើនពីការរាយការណ៍ករណី និងបានចងក្រងរក្សាទុកជាឯកសារដោយអង្គការលីកាដូក្នុង ឆ្នាំ ២០០២-២០០៣ ក៏ដូចជាការធ្វើការស្រាវជ្រាវបន្ថែមអំពីបញ្ហារំលោភសេពសន្ថវៈ និងការបៀតបៀនកេរ្តិ៍ខ្មាស់នៅកម្ពុជា ។

[៣] វិសាលភាពនៃរបាយការណ៍នេះ បានរួមបញ្ចូលនូវករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ ប៉ុន្តែមិនបានលើកឡើងពីបញ្ហាជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ អំពើអនាចារ និងទាសករផ្លូវភេទទេ ។

[៤] ប៉ុន្តែ ក្នុងចំណោម ៥៦ករណីនេះ មានករណី ៦ ដែលជនល្មើសមិនត្រូវចាប់ខ្លួននៅឡើយ និងករណីមាន ២ករណីបានកាត់ទោសជនល្មើសជាច្រើននាក់ គឺមានតែជនល្មើសម្នាក់ប៉ុណ្ណោះដែលត្រូវបានដាក់ក្នុងពន្ធនាគារ ។

ស្រាយតាមរយៈការសងជំងឺចិត្តក្រៅប្រព័ន្ធច្បាប់តុលាការ ដែលរត់ការដោយមន្ត្រីមួយចំនួនផងដែរ ។ អង្គការលីកាដូក៏ខ្វាយខ្វល់ផងដែរចំពោះការប្រព្រឹត្តិបែបនេះ ដែលធ្វើអោយប៉ះពាល់មកលើសុឆន្ទៈ របស់ជនរងគ្រោះដែលចង់រាយការណ៍ពីករណីដែលកើតឡើងចំពោះរូបគេ និងលទ្ធភាពរបស់ពួកគេក្នុងការស្វែងរកជំនួយផ្នែកច្បាប់ ដែលត្រូវអនុញ្ញាតដោយច្បាប់នោះ ។

## ១. ជនរងគ្រោះវ័យក្មេង  ករណីដែលដាក់បណ្តឹង និងមិនដាក់បណ្តឹង

### ក. ចំនួនករណីរំលោភសេពសន្ថវៈ និងបៀតបៀនក្មេងខ្ចីដែលត្រូវបានរាយការណ៍មានការកើនឡើងជាលំដាប់

លីកាដូបានស៊ើបអង្កេតលើ ១៧៩ករណីរំលោភក្នុងឆ្នាំ ២០០២ និងស៊ើបអង្កេតលើ ១៧៧ករណី រំលោភក្នុងឆ្នាំ ២០០៣ កន្លងមកនេះ ហើយបើប្រៀបធៀបទៅឆ្នាំ ២០០១ មានតែ ១៤៦ករណីប៉ុណ្ណោះ ដែលត្រូវបានរាយការណ៍ ។ សមាគម អាដហុកដែលជាអង្គការសិទ្ធិមួយផ្សេងទៀតក៏បានលើកឡើងអំពីការកើនឡើងនូវការរាយការណ៍លើអំពីករណីរំលោភសេពសន្ថវៈដូចគ្នានេះដែរ  នៅក្នុងឆ្នាំ ២០០៣ អង្គការនេះបានទទួលរបាយការណ៍អំពីករណីរំលោភសេពសន្ថវៈនេះចំនួន ៣៥៦ករណី ហើយបើប្រៀបធៀបទៅនឹងឆ្នាំ២០០២ អង្គការនេះបានទទួលត្រឹមតែ ២៩៧ ករណីតែប៉ុណ្ណោះ និងឆ្នាំ ២០០១ ទទួលបានត្រឹមតែ ១៨២ករណីគត់[៥] ។

### ខ. ករណីដែលមិនបានដាក់បណ្តឹង

លីកាដូមានការខ្វាយខ្វល់យ៉ាងខ្លាំង ជាពិសេសចំពោះករណីដែលបានរាយការណ៍ទាំងឡាយ ដោយវាគ្រាន់តែជាផ្នែកមួយនៃបទឧក្រិដ្ឋដែលប្រព្រឹត្តិនៅកម្ពុជាតែប៉ុណ្ណោះ ។ មានកត្តាជាច្រើនដែលបានជំរុញអោយជនរងគ្រោះ មិនរាយការណ៍នូវបទឧក្រិដ្ឋមួយចំនួន និងមិនចង់ចាត់វិធានការតាមផ្លូវច្បាប់ផងដែរ ។

- **ការមិនទុកចិត្តប្រព័ន្ធយុត្តិធម៌:** ពលរដ្ឋជាច្រើនមានការសង្ស័យថា គេមិនបានធ្វើការពិចារណាយ៉ាងល្អិតល្អន់ទៅលើករណីរបស់ជនរងគ្រោះទេ ។
- **ការចំណាយប្រាក់កាសក្នុងការប្តឹង:** ជនរងគ្រោះត្រូវចំណាយថវិកាដើម្បីទទួលបាននូវលិខិតកោសល្យវិច្ឆ័យ និងសូកមន្ត្រីខ្លះដើម្បីអោយមានការស៊ើបអង្កេត ទោះបីជាករណីបទឧក្រិដ្ឋមិនគួរអោយមានការចំណាយ ហើយការកាត់ទោសគួរតែត្រូវបានចំណាយទាំងស្រុងក៏ដោយ ។
- **ការសម្រុះសម្រួលដោះស្រាយតាមការសងជំងឺចិត្តដោយខុសច្បាប់:** ដំណោះស្រាយបែបនេះខុសច្បាប់ទាំងស្រុងចំពោះករណីព្រហ្មទណ្ឌ ។ ការធ្វើបែបនេះបានជំរុញអោយជនល្មើសជឿថាគេអាចប្រព្រឹត្តិបទល្មើសដោយគ្មានទោសទណ្ឌ ព្រមទាំងបង្ហាញអោយឃើញថា ជនរងគ្រោះមិនត្រូវបានជួយការពារដោយគតិយុត្តិ និងថែមទាំងមិនបានការពារពេញលេញខាងផ្លូវច្បាប់ឡើយ ។

[៥] សមាគម អាដហុក- រំលោភ : តវិយាបទ និងដំណោះស្រាយនៅកម្ពុជា ( សេចក្តីព្រាង ) ខែមករា ឆ្នាំ ២០០៤ ទំព័រ ១២ ចំណាំ: ករណីដែលត្រូវបានរាយការណ៍ទៅអាដហុកអាចត្រួតគ្នាជាមួយករណីដែលរាយការណ៍ទៅលីកាដូដែរ  នៅក្នុងក្របខណ្ឌពេលវេលាដូចគ្នា ។
អាដហុកមានការិយាល័យតាមបណ្តាខេត្តចំនួន ២៤ និងការិយាល័យកណ្តាលនៅភ្នំពេញ ។

- **ការស្តីបន្ទោសខុសទំនង:** ការយល់ខុសដែលគេតែងតែស្តីបន្ទោសជនរងគ្រោះអំពីករណី រំលោភសេពសន្ថវៈនេះកើតឡើងដែលធ្វើអោយមានការអាម៉ាស់ និងជំរុញអោយជនរងគ្រោះ ឬគ្រួសាររបស់គេមិនចង់ធ្វើបណ្តឹង ។

- **ជំនឿអំពីព្រហ្មចារី:** មនុស្សជាច្រើនជឿថា ប្រសិនបើក្រដាសព្រហ្មចារីមិនរហែកទេនោះមិនគ្រប់គ្រាន់ក្នុងការចោទថាជាបទរំលោភទេ ។ ជាលទ្ធផល ជនរងគ្រោះក្នុងករណីរំលោភមួយចំនួនដែលធ្លាប់បានរួមរ័ក្សរួចមកហើយនោះ ជឿជាក់ថា ដោយហេតុមិនអាចបង្ហាញនូវការដាច់រហែកព្រហ្មចារីបាននោះមិនអាចបញ្ជាក់ការពិតនៃបទល្មើសបានឡើយ ។

- **ការបាត់បង់នូវព្រហ្មចារី:**[៦] នៅពេលណាដែលមានការបាត់បង់ព្រហ្មចារីក្នុងពេលរំលោភ នោះវាជាការអាមាសជាទីបំផុត (ជាជាងការដាក់ទណ្ឌកម្មជនសង្ស័យទៅទៀត) ជាធម្មតាវាច្រើនតែក្លាយទៅជាចំណុចសំខាន់បំផុតចំពោះជនរងគ្រោះ និងគ្រួសាររបស់ពួកគេ ។

- **ខ្លាចមានការគុំគួន:** ក្នុងករណីដែលជនល្មើសជាជនមានអំណាចលើជនរងគ្រោះ (សមាជិកគ្រួសារ នគរបាល យោធា ឬអ្នកមានដែលមានអំណាច) ជនរងគ្រោះ និងគ្រួសាររបស់គេគិតថាប្តឹងទៅក៏មិនឈ្នះគេនឹងបានលទ្ធផលអវិជ្ជមាន ហេតុដូច្នេះក៏មិនបន្តបណ្តឹងតទៅទៀតទេ ។

## គ. ជនរងគ្រោះ : អ្នកដែលរងគ្រោះជាងគេបំផុត គឺអ្នកមានអាយុក្មេងបំផុតនៅកម្ពុជា

ចំនួនករណីដែល ត្រូវបានរាយការណ៍ គឺបានប៉ះពាល់ដល់នារីវ័យក្មេង និងកុមារី ជាវិសមាមាត្រ ។ នៅក្នុងឆ្នាំ ២០០២ ៩១.៦% នៃជនរងគ្រោះដែលលីកាដូបានស៊ើបអង្កេតជាជនរងគ្រោះដែលមានអាយុ ១៨ឆ្នាំ ឬតិចជាងនេះ [៧]។ ២៩.២% គឺមានអាយុ១២ឆ្នាំ ឬតិចជាង និង ៦%គឺមានអាយុ ៥ឆ្នាំ ឬតិចជាង ។ ក្នុងឆ្នាំ ២០០៣ កន្លងមកនេះ ៧៧.៨% នៃជនរងគ្រោះដែលអង្គការលីកាដូបានស៊ើបអង្កេតមានអាយុក្រោម ១៨ឆ្នាំ ។ ៤១.១% នៃជនរងគ្រោះមានអាយុ ១២ឆ្នាំ ឬទាបជាងនេះ ហើយ ៨.៧%ទៀត មានអាយុ ៥ឆ្នាំ ឬទាបជាងនេះទៅទៀត [៨] ។

មានភស្តុតាងមួយដែលយើងអាចនិយាយថា ករណីរំលោភលើកុមារភាគច្រើនត្រូវបានរាយការណ៍ ។ ការខ្វាយខ្វល់របស់មាតាបិតា និងសហគមន៍ចំពោះកុមារ និងការប្រព្រឹត្តិបទឧក្រិដ្ឋដែលបំពានហួសប្រមាណអាចផ្តល់នូវហេតុផលថាហេតុអ្វីបានជាសមាជិកគ្រួសារ និងសហគមន៍រាយការណ៍ករណីរំលោភលើកុមារច្រើនជាងករណីរំលោភមកលើ

---

[៦] នៅក្នុងសង្គម និងក្នុងលំដាប់នយោបាយកម្ពុជា គេបានអោយតំលៃខ្ពស់ទៅលើព្រហ្មចារីរបស់នារីហើយមានការត្រួតពិនិត្យដោយបង្ខំទៅលើសកម្មភាពភេទរបស់នារី-រេបេកា សឺបទី : រំលោភសេពសន្ថវៈ និងការរំលោភផ្លូវភេទក្នុងសង្គមកម្ពុជា "ចាប់ពីអំពើហិង្សាប្រឆាំងស្ត្រីនៅក្នុងសង្គមអាស៊ី" ទំព័រ ១០៤ កែសំរួលដោយអែលម័រ មែនជីសុន និងលីនដា រ៉ាប៊ែនេត នៃសកលវិទ្យាល័យម៉ាការី បោះពុម្ពនៅញូវយក ឆ្នាំ២០០៣ ។

[៧] ពាក្យបណ្តឹងមួយចំនួនដែលត្រូវបានស៊ើបអង្កេតនៅឆ្នាំ ២០០២ ករណីខ្លះមានជនល្មើសច្រើននាក់ ។ ចំនួនជនរងគ្រោះសរុបមាន ២០២នាក់ ។

[៨] ក្នុងឆ្នាំ ២០០៣ លីកាដូបានស៊ើបអង្កេតករណីរំលោភសេពសន្ថវៈ ១៧៧ករណី ដែលមានជនរងគ្រោះ ១៨៥នាក់ ។

មនុស្សពេញវ័យ ។ ជាពិសេស នារីពេញវ័យដែលបានរៀបការរួចហើយ គឺមិនសូវវាយការណ៍អំពីករណើរំលោភសេព សន្ថវៈនេះទេ ។

## ២. យុត្តាធិការដែលការពារជនរងគ្រោះ

ក្រោមច្បាប់កម្ពុជា ករណីរំលោភសេពសន្ថវៈ គឺជាបទល្មើសព្រហ្មទណ្ឌ ។ ជនរងគ្រោះមានសិទ្ធិប្រើប្រាស់ប្រព័ន្ធយុត្តិធមិ និងកែច្នៃអោយបានប្រសើរឡើងវិញ ដូចដែលបានធានានៅក្នុងច្បាប់របស់ប្រទេសក៏ដូចជាច្បាប់អន្តរជាតិ ។ ការសម្របសម្រួលដំណោះស្រាយបទល្មើសព្រហ្មទណ្ឌ (ដូចជា ករណីរំលោភសេពសន្ថវៈនិងបៀតបៀនកេរ្តិ៍ខ្មាស់) ត្រូវបានហាមឃាត់ដោយច្បាប់កម្ពុជា[៩] ។

## ក_ការហាមឃាត់នៃរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ដោយច្បាប់ព្រហ្មទណ្ឌកម្ពុជា

អំពើរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ជាអំពើខុសច្បាប់ក្រោមក្រមព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២ ហើយច្បាប់ឆ្នាំ ២០០១ បានដាក់ស្ថានទំងន់កាន់តែធ្ងន់ធ្ងរចំពោះបទឧក្រិដ្ឋ [១០]។ រំលោភសេពសន្ថវៈគឺជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានកំណត់ន័យថា "រាល់អំពើផ្លូវភេទទាំងឡាយណា ដែលប្រព្រឹត្តិដោយបំពានទៅលើជនណាម្នាក់ទៀតដោយពុំមានការយល់ព្រមពីជននោះ" [១១]។ ការប្រព្រឹត្តិ ឬការប៉ុនប៉ងប្រព្រឹត្តិរំលោភ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ ទៅ ២០ ឆ្នាំ [១២] ។

អំពើបៀតបៀនកេរ្តិ៍ខ្មាស់ជាបទល្មើសកំរិតស្រាល ។ ត្រូវបានកំណត់ន័យថា "ការរំលោភផ្នែកភេទលើអ្នកដទៃទាំងពីរភេទ ដោយការប៉ះពាល់ ស្ទាបអង្អែល ឬដោយប្រព្រឹត្តិនូវអំពើភេទផ្សេងៗដោយពុំមានការបំពាន"[១៣] ។ ទោសទណ្ឌចំពោះការប្រព្រឹត្តិអំពើបៀតបៀនកេរ្តិ៍ខ្មាស់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ទៅ ៣ ឆ្នាំ [១៤] នឹងត្រូវផ្តន្ទាទោសទ្វេរ ប្រសិនបើជនរងគ្រោះមានអាយុក្រោម ១៦ ឆ្នាំ [១៥] ។

## ខ_ ប្រព័ន្ធតុលាការត្រូវអនុវត្តច្បាប់យ៉ាងហ្មត់ចត់នឹងឥតលំអៀង

រាល់ការវិនិច្ឆ័យដោយតុលាការត្រូវស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[១៦]។ ក្រោមច្បាប់រដ្ឋធម្មនុញ្ញតួនាទី និងភារកិច្ចរបស់តុលាការគឺដើម្បីលើកកំពស់ច្បាប់ដោយឥតលំអៀង និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋទូទៅ[១៧] ។

---

[៩] ច្បាប់រដ្ឋកម្ពុជា ស្តីពីនីតិវិធី (ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ) មាត្រា ២ និង ៧ សូមអានផ្នែក ៥ ខាងក្រោម-សម្រុះសម្រួលដោះស្រាយខុសច្បាប់ដោយមន្ត្រី ។

[១០] អាជ្ញាធរបណ្តោះអាសន្នកម្ពុជា -មាត្រាទាំងឡាយទាក់ទងទៅនឹងប្រព័ន្ធតុលាការ និងច្បាប់ព្រហ្មទណ្ឌ និងនីតិថិធីព្រហ្មទណ្ឌអនុវត្តនៅកម្ពុជាក្រោមសម័យអន្តរកាលមានៈ (ក្រមព្រហ្មទណ្ឌអ៊ុនតាក់) ក្រមព្រហ្មទណ្ឌអ៊ុនតាក់ត្រូវព្រាងឡើងដោយអ៊ុនតាក់ហើយត្រូវបានសំរេចដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា នៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

[១១] ក្រមព្រហ្មទណ្ឌអន្តរកាល មាត្រា ៣៣ -ច្បាប់ស្តីពីការដាក់ស្ថានទំងន់ទៅលើបទល្មើសឧក្រិដ្ឋ មាត្រា ៥ -ច្បាប់អនុម័តដោយរដ្ឋសភាជាតិ នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០១ ។

[១២] ច្បាប់ស្តីពីការដាក់ស្ថានទំងន់ទោសនៃបទល្មើសព្រហ្មទណ្ឌ -មាត្រា ៥ ។

[១៣] ក្រមព្រហ្មទណ្ឌអ៊ុនតាក់ -មាត្រា ៤២ ។

[១៤] ក្រមព្រហ្មទណ្ឌអ៊ុនតាក់ -មាត្រា ៤២ ។

[១៥] ក្រមព្រហ្មទណ្ឌអ៊ុនតាក់ -មាត្រា ៤២ (២) ។

មានតែចៅក្រមប៉ុណ្ណោះដែលមានសិទ្ធិក្នុងការវិនិច្ឆ័យសំរេចសេចក្តី ។ ចៅក្រម ត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយត្រូវគោរពច្បាប់យ៉ាងហ្មត់ចត់ ស្មោះត្រង់ និងប្រកបដោយមនសិការ[១៨] ។ ក្រោមច្បាប់នីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជា ករណីព្រហ្មទណ្ឌគឺជាបណ្តឹងសាធារណៈហើយការដោះស្រាយតាមផ្លូវឯកជនគឺជាការអនុវត្តន៍មិនយុត្តិធម៌ ដូច្នេះត្រូវផ្តន្ទាទោសដោយវិធានការដាក់វិន័យ ឬដាក់ពន្ធនាគារ[១៩] ។

## គ. គោលការណ៍ច្បាប់អន្តរជាតិដែលដាក់ពិកល់ប្រើនៅក្នុងច្បាប់កម្ពុជា

- **ច្បាប់សិទ្ធិមនុស្សអន្តរជាតិៈ**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដែលបានចែងនៅក្នុងច្បាប់អន្តរជាតិនានារួមមានសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ក៏ដូចជាកតិកាសញ្ញា និងអនុសញ្ញានានាដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ ដូចជាអនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញាស្តីពីការលុបបំបាត់ចោលគ្រប់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ[២០] ។ ក្រមព្រហ្មទណ្ឌអន្តរកាលក៏បានតំរូវអោយប្រកាន់ខ្ជាប់ផងដែរនូវច្បាប់អន្តរជាតិមួយចំនួនដែលទាក់ទងនឹងអំពើរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់នេះ[២១] ។

- **ស្វែងរកភាពយុត្តិធម៌**

ជនរងគ្រោះនៃបទឧក្រិដ្ឋទាំងឡាយមានសិទ្ធិប្រើប្រាស់យន្តការយុត្តិធម៌ និងទទួលបានការតបស្នងនូវជំងឺចិត្តជួសជុលការខូចខាតដែលគេបានទទួលរងភ្លាមៗ ដែលផ្តល់ដោយនិតិកម្មជាតិ[២២] ។

- **ការតបសងជម្ងឺចិត្តជួសជុលដោយប្រសិទ្ធិភាព**

មនុស្សគ្រប់រូបមានសិទ្ធិក្នុងការទទួលការជួសជុលកែលំអដោយយន្តការយុត្តិធម៌ ចំពោះអំពើរំលោភសិទ្ធិជាមូលដ្ឋានដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់នានា[២៣] ។

---

[១៦] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តដោយសភាធម្មនុញ្ញនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣- វិសោធនកម្មនៅថ្ងៃទី ៤ ខែមិនា ឆ្នាំ ១៩៩៩ ។ (រដ្ឋធម្មនុញ្ញ) មាត្រា ១៥០ ។

[១៧] រដ្ឋធម្មនុញ្ញ -មាត្រា ១២៨ ។ សូមអានក្រមព្រហ្មទណ្ឌអ៊ុនតាក់ មាត្រា ១ ។

[១៨] រដ្ឋធម្មនុញ្ញ -មាត្រា ១២៩ ។ សូមអានច្បាប់អ៊ុនតាក់ មាត្រា ១ ( ១ ) ។

[១៩] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ -មាត្រា ២ និង៧ - ចំណុច ១០ ខាងលើ ។

[២០] រដ្ឋធម្មនុញ្ញមាត្រា ៣១ ។

[២១] ក្រមព្រហ្មទណ្ឌអន្តរកាល -មាត្រា ១ (១) -មាត្រា ១ ឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងសេចក្តីប្រកាសនៃគោលការណ៏គ្រឹះនៃយុត្តិធម៌ចំពោះជនរងគ្រោះដោយសារបទឧក្រិដ្ឋ និងការរំលោភដោយអំណាចអនុម័តដោយសេចក្តីសំរេចមហាសន្និបាតលេខ ៤០/៣៤ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១១៩៨៥ ក្រមព្រហ្មទណ្ឌអន្តរកាល- មាត្រា ២៧ (២) ។

[២២] សេចក្តីប្រកាសគោលការណ៏គ្រឹះនៃយុត្តិធម៌ចំពោះជនរងគ្រោះដោយបទឧក្រិដ្ឋ និងការរំលោភដោយអំ ណាច - មាត្រា ៤ ។

[២៣] សេចក្តីថ្លែងការណ៏ជាសកលស្តីពីសិទ្ធិមនុស្ស -មាត្រា ៨ ។ សំខាន់ដូចគ្នានៅមាត្រា ១០ និង ១១ នៃសេច ក្តីថ្លែងការណ៏នេះ ។ សិទ្ធិក្នុងការទទួលបាននូវការផ្តន្ទាទោសយុត្តិធម៌របស់ជនជាប់ចោទត្រូវបានធានាផងដែរ ក្រោមមាត្រា ១៤ កត្តិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។

- ## សមភាពចំពោះមុខច្បាប់

ពលរដ្ឋកម្ពុជាគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។ គោលការណ៍គ្រឹះនេះបានតំកល់នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ[២៤] និងក្នុងច្បាប់អន្តរជាតិ[២៥] ធានាដល់ពលរដ្ឋគ្រប់រូបត្រូវបានការពារយ៉ាងពេញលេញដោយច្បាប់ ដោយមិនគិតពី ជាតិ សាសន៍ ពណ៌សម្បុរ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ប្រភពកំណើតស្ថានភាពសង្គម ទ្រព្យសម្បត្តិ ឬស្ថានភាពផ្សេងៗទៀតឡើយ ។ ក្រោមគោលការណ៍នេះ នារីបំរើផ្លូវភេទ ឬសមាជិកនៃក្រុមជនជាតិភាគតិចត្រូវបានទទួលកិច្ចការពារដូចៗគ្នាក្រោមច្បាប់នេះដូចជនកម្ពុជាផ្សេងៗទៀតដែរ ។

- ## កិច្ចការពារជាពិសេសចំពោះកុមារនិងស្ត្រី

ច្បាប់រដ្ឋធម្មនុញ្ញបានឆ្លុះបញ្ចាំងនូវគោលនយោបាយរបស់រដ្ឋ ក្នុងការផ្តល់កិច្ចការពារជាពិសេសចំពោះកុមារ[២៦] និងស្ត្រី[២៧] ។ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅឆ្នាំ១៩៩២ ។ មាត្រា៣៤ នៃច្បាប់នេះបានកំណត់កាតព្វកិច្ចដល់រដ្ឋជាភាគីនានាអោយការពារកុមារពីគ្រប់ទំរង់នៃអាជីវកម្ម និងការរំលោភផ្លូវភេទទាំងអស់ ។ ព្រះរាជាណាចក្រកម្ពុជាក៏បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលប់បំបាត់ចោលនូវគ្រប់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅឆ្នាំ ១៩៩២ ដែលផ្តល់នូវសមភាពរវាងស្ត្រី និងបុរសចំពោះមុខច្បាប់[២៨] ។

---

[២៤] រដ្ឋធម្មនុញ្ញ -មាត្រា ៣១ ។

[២៥] សេចក្តីថ្លែងការណ៍ជាសកល -មាត្រា ៧ កត្តិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ- មាត្រា ២៦ ។

[២៦] រដ្ឋធម្មនុញ្ញ-មាត្រា ៤៨ ដែលទទួលស្គាល់ការអនុវត្តន៍អនុសញ្ញាស្តីពីសិទ្ធិកុមារនៅក្នុងច្បាប់កម្ពុជា ។

[២៧] រដ្ឋធម្មនុញ្ញ -មាត្រា ៤៥ ចែងថា" រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទនឹងត្រូវលប់បំបាត់ចោល" ។

[២៨] ជាពិសេស សូមអាន មាត្រា ៥ និង ១៥ ។

## ៣. តួនាទីរបស់តុលាការ

ច្បាប់ក្នុងប្រទេស និងអនុសញ្ញាអន្តរជាតិនានាវានឹងក្លាយទៅគ្មានន័យអ្វីសោះ ប្រសិនបើតុលាការគ្រប់លំដាប់ថ្នាក់មិនអនុវត្ត ។ ការបកស្រាយអត្ថន័យច្បាប់ដោយគតិយុត្តិ និងការអនុវត្តន៍ច្បាប់ដោយតុលាការ បុគ្គលិកតុលាការ និងមន្ត្រីអនុវត្តច្បាប់នានាមានតួនាទីយ៉ាងសំខាន់នៅក្នុងការការពារ និងការផ្តន្ទាទោសដល់អំពើរំលោភផ្លូវភេទនៅព្រះរាជាណាចក្រកម្ពុជា ។

### ក. ឧបសគ្គទាំងឡាយដែលប្រព័ន្ធតុលាការកម្ពុជាប្រឈមមុខ

ការលំបាកទាំងឡាយដែលតុលាការកម្ពុជាប្រឈមមុខ គឺមានការដឹងឮជាទូទៅព្រមទាំងត្រូវបានរាយការណ៍យ៉ាងទូលំទូលាយទៀតផង ។

"ការពួតផ្គុំនូវស្ថានភាពដ៏ក្រីក្រនានារួមមានប្រាក់បៀវត្សរ៍តិចតួច ការជ្រៀតជ្រែក ដោយអង្គការនិតិប្រតិបត្តិ កង្វះការអប់រំ និងការហ៊ឹកហ៊ឺន ព្រមទាំងការអនុវត្តន៍ច្បាប់ដ៏ទន់ខ្សោយ វាបានបង្កើតនូវប្រព័ន្ធតុលាការមួយដែលប្រជាពលរដ្ឋគ្មានជំនឿ ថែមទាំងជួបប្រទះនឹងការបរាជ័យនៅក្នុងភារកិច្ច និងការទទួលខុសត្រូវជាប្រចាំរបស់ខ្លួនទៀតផង[២៩] ។"

#### • កង្វះខាតនិតិបញ្ញត្តិ

តុលាការក៏បានប្រឈមនឹងការលំបាកផងដែរក្នុងការអនុវត្តន៍ការងារផ្នែកច្បាប់ នោះគឺភាពមិនស្រប និងភាពមិនពេញលេញ ។ ចំណុចដែលខ្វាយខ្វល់ពិសេសគឺកង្វះនូវនិយមន័យនៃពាក្យ ***យល់ព្រម*** និងមធ្យោបាយក្នុងការកំណត់សមត្ថភាពក្នុងការយល់ព្រមនៅក្នុងច្បាប់ព្រហ្មទណ្ឌ ។ យល់ព្រមតាមដោយពុំមានការរើបំរាស់ដោយសារការភ័យខ្លាចនេះពុំមែនជាការយល់ព្រមទេ ។ យល់ព្រមតាមដោយពុំមានរើបំរាស់ ដោយសារកង្វះសមត្ថភាពផ្នែកសតិបញ្ញា ការបំពុល ឬភាពស្រវឹង ឬជំងឺផ្លូវចិត្តទាំងនេះក៏ពុំមែនជាការយល់ព្រមដែរ ។ អវត្តមានចំណុចផ្សេងៗទៀតនៅក្នុងច្បាប់ព្រហ្មទណ្ឌមានមាត្រាដូចជាលក្ខខណ្ឌនៃស្ថានភាពរំលោភ រំលោភផ្លូវភេទក្នុងចំណងអាពាហ៍ពិពាហ៍សាហាយស្មន់ និងការកំណត់និយមន័យនៃពាក្យអនិតិជនជាដើម ។

#### • កង្វះធនធាន និងការហ៊ឹកហ៊ឺន

យើងហ៊ានទាញការសន្និដ្ឋានដោយឥតសង្ស័យថា ប្រាក់បៀវត្សតិចតួចនាំអោយមានអំពើពុករលួយ ។ ប្រាក់បៀវត្សរបស់ក្រឡាបញ្ជីតុលាការនៅមានកំរិតទាបជាទីបំផុត ។ លើសពីនេះទៅទៀត កង្វះថវិកាសំរាប់ធ្វើការស៊ើបអង្កេតទៅក្នុងករណីដែលមានកំរិតខ្ពស់គឺត្រូវការចាំបាច់បំផុតចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរ ។ កង្វះបុគ្គលិក

---

[២៩] អង្គការលើកលែងទោសអន្តរជាតិ-របាយការណ៍ឆ្នាំ ២០០៣ ( លើកលែងទោសអន្តរជាតិ ក្រុងឡុងដ៍ ២០០៣) ចំណុច ៦៥ ។ របាយការណ៍បានសរសេរក្នុងអំឡុងពេលចាប់ពី ខែមករា ដល់ ខែធ្នូ ឆ្នាំ ២០០២ ។

ដែលមានការហ៊ឹកហ៊ឺនគ្រប់គ្រាន់ដើម្បីប្រឈមទៅនឹងករណីយ៉ាងច្រើន និងបញ្ជីករណីព្រហ្មទណ្ឌគរជាគំនរយ៉ាងវែងអន្លាយ ។

### ◆ ព្រះរាជអាជ្ញា ចៅក្រម ក្រឡាបញ្ជី កាតព្វកិច្ចផ្សេងៗគ្នា

ការសំភាសន៏ដែលអង្គការលីកាដូបានធ្វើឡើងជាមួយក្រឡាបញ្ជីតុលាការ និងចៅក្រមកាលពីខែ ឧសភា ឆ្នាំ២០០៣ កន្លងទៅបានបង្ហាញអោយឃើញនូវការយល់ច្រឡំ និងចាត់តាំងភារកិច្ចខុសនៅក្នុងតុលាការ ។ ការសំភាសន៍បានបញ្ជាក់យ៉ាងច្បាប់ថា ចៅក្រម ច្រើនតែធ្វើប្រតិភូកម្ម (ផ្ទេរអំណាចការងារ) នូវភារកិច្ចស៊ើបអង្កេត និងវិនិច្ឆ័យ សេចក្តីទៅអោយក្រឡាបញ្ជី ដែលការអនុវត្តន៏បែបនេះជាការរំលោភផ្ទាល់ទៅលើមាត្រា ១២៩ នៃច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ជំពូក ៤ ។

គ្រោះថ្នាក់មួយក្នុងការអនុញ្ញាតអោយមានការអនុវត្តន៏បែបនេះ គឺក្រឡាបញ្ជីច្រើនតែខ្វះការអប់រំផ្នែកច្បាប់ ឬផ្នែកស៊ើបអង្កេត ។ វាអាចមានភាពខុសឆ្គងនៅក្នុងច្បាប់ និងនីតិវិធី នៅពេលក្រឡាបញ្ជីដែលមានចេតនាល្អ ហើយកំពុងអនុវត្តការងារដ៏ច្រើនលើសលប់ ។ ចំណុចនេះបានចោទជាការគំរាមកំហែងឡើងឥតឈប់ឈរទៅលើជនរងគ្រោះ និងជនជាប់ចោទ ថែមទាំងអាចធ្វើអោយប៉ះពាល់ដល់សិទ្ធិទទួលបាននូវភាពយុត្តិធម៌របស់ជនរងគ្រោះដែលអ្នក ទន់ខ្សោយជាទីបផុតនោះផង[៣០] ។

### ◆ កង្វះការត្រួតពិនិត្យលើប្រព័ន្ធតុលាការ

ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម មានតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់ព្រះមហាក្សត្រ ដើម្បីធានានូវឯករាជ្យភាពរបស់ប្រព័ន្ធតុលាការនិងការដាក់វិន័យដល់ចៅក្រម[៣១] ។ ប៉ុន្តែចាប់តាំងពីបានកកើតឡើងតាំងពីឆ្នាំ១៩៩៤មក ស្ថានប័ននេះបានក្លាយជាអសកម្ម និងគ្មានដំណើរការក្នុងការប្រយុទ្ធទប់ទល់នឹងអំពើពុករលួយអោយមានប្រសិទ្ធិភាពបន្តិចណាទាល់តែសោះ ភាពគ្មានច្បាប់ ឬការមិនយកចិត្តទុកដាក់របស់ចៅក្រមជាទូទៅឡើយ ។

## ខ. ការលំបាកពាក់ព័ន្ធនឹងការស៊ើបអង្កេត

ការរំលោភផ្លូវភេទ គឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរ និងការផ្តន្ទាទោសដាក់ពន្ធនាគារគឺជាការផ្តន្ទាទោសមួយយ៉ាង សមរម្យ ។ ដូច្នេះ ចាំបាច់ការវិនិច្ឆ័យទោសត្រូវតែផ្អែកទៅលើការប្រមូលភស្តុតាងដែលធ្វើឡើងដោយត្រឹមត្រូវព្រមទាំងស្របនឹងអង្គហេតុដែលបទល្មើសបានកើតឡើង ។

---

[៣០] ចំពោះពត៌មានបន្ថែមអំពីការបកស្រាយច្បាប់ខុសដោយក្រឡាបញ្ជី សូមអានផ្នែកទី ៤ - *ករណីសិក្សាអំពី ការបកស្រាយច្បាប់ខុស* ខាងក្រោម ។

[៣១] រដ្ឋធម្មនុញ្ញ -មាត្រា ១៣៣ -១៣៤ ។

## • ការប្រមូលភស្តុតាង

ចៅក្រមស៊ើបអង្កេតលើកឡើងជាសាធារណៈថា ជារឿយៗពួកគាត់មិនដែលមានថវិកាគ្រប់គ្រាន់សំរាប់ធ្វើបេសកកម្មចុះស៊ើបអង្កេតប្រមូលភស្តុតាងនៅតាមខេត្តនានាទេ ។ ពួកគាត់ជឿជាក់យ៉ាងខ្លាំងទៅលើការសារភាព និងរបាយការណ៍របស់ប៉ូលីស។ យោងតាមចៅក្រមមួយរូបដែលបានផ្តល់ការសំភាសន៍កាលពីខែ ឧសភា ឆ្នាំ២០០៣ កន្លងទៅបានអោយដឹងថា ប្រភេទភស្តុតាងដ៏សំខាន់បំផុតដែលប្រើប្រាស់ក្នុងការវិនិច្ឆ័យសេចក្តីនោះ គឺចំលើយសារភាពរបស់ជនសង្ស័យ លិខិតកោសល្យវិច្ច័យ និងការសំភាសន៍ជាមួយជនរងគ្រោះ ។ ភស្តុតាងសំខាន់ៗផ្សេងទៀតរួមមានៈ ស្នាមដាច់រហែកនៃសំលៀកបំពាក់ កោសល្យវិច្ច័យនៃទឹកកាម និងឈាមដែលបានមកពីរាងកាយនៃជនរងគ្រោះ ។ ប៉ុន្តែដោយសារការអៀនខ្មាស់ ឬការភ័យខ្លាចរបស់ជនរងគ្រោះ និង/ឬគ្រួសាររបស់ពួកគេ ជាធម្មតាពួកគេមិនដែលដឹង ថាតុលាការត្រូវការលិខិតកោសល្យវិច្ច័យដើម្បីបង្កសុំណុំរឿងប្តឹងទេ ឬក៏ពួកគេមានការស្ទាក់ស្ទើរក្នុងធ្វើលិខិតបែបនេះ ឬជួបការលំបាកក្នុងការធ្វើលិខិតកោសល្យវិច្ច័យនេះ ។

ការប្រមូលភស្តុតាងបានក្លាយទៅជាការងារដ៏លំបាកមួយ នៅពេលដែលពេលវេលាបានកន្លងផុតទៅរវាងបទឧក្រិដ្ឋកើតឡើងនិងការបង្កសំណុំរឿងប្តឹង ។ ក្នុងខណៈដែលពុំមានឧបករណ៍ស៊ើបអង្កេតដ៏ទាន់សម័យនោះ (ដូចជាការធ្វើពិសោធន៍ ឌី អិន អេ) ដើម្បីបញ្ជាក់អោយប្រាកដថា ជនដែលជាប់ពាក់ព័ន្ធនៅក្នុងរឿងទាំងឡាយត្រូវតែមានមុខនៅក្នុងសវនាការ ហើយការវិនិច្ឆ័យក្តីត្រូវបានស្នើឡើង ដែលជាវិធីមួយដើម្បីធ្វើអោយបទឧក្រិដ្ឋមួយមានរូបភាពពេញលេញជាងមុន ។ លទ្ធភាពអាចធ្វើបែបនេះបានតំរូវអោយមានសាក្សីនានា ការអនុវត្តន៏ច្បាប់ និងអ្នកជំនាញខាង ព្រហ្មទណ្ឌជាដើម ។

## • ការពឹងផ្អែកលើលិខិតកោសល្យវិច្ច័យ និង ភស្តុតាងនៃការបង្ខំ

ក្នុងការវិនិច្ឆ័យករណីរំលោភសេពសន្ថវៈ ចៅក្រមពឹងផ្អែកយ៉ាងខ្លាំងទៅលើការធ្វើកោសល្យវិច្ច័យដោយគ្រូពេទ្យនៃមន្ទីរពេទ្យរដ្ឋថ្នាក់ស្រុក ឬខេត្ត ។ តុលាការក៏ត្រូវការភស្តុតាងពីការរើបំរាស់ ឬប្រតាយប្រតប់ផងដែររួមមានរបួសលើកេរ្តិ៍ភេទ និងផ្នែកផ្សេងទៀតនៃរាងកាយ ស្នាមជាំ និងឈាមដោយការរហែកក្រដាសព្រហ្មចារីរបស់ស្ត្រី ។ ប៉ុន្តែមិនមែនគ្រប់ករណីរំលោភសេពសន្ថវៈទាំងអស់សុទ្ធតែប្រព្រឹត្តិដោយអំពើហិង្សានោះទេ ។ ជំនឿដែលតែងតែជឿ ខុសមួយគឺការជឿថារាល់អំពើរំលោភសេពសន្ថវៈទាំងអស់នឹងបន្សល់ទុកនូវស្លាកស្នាមរបួសធ្ងន់ធ្ងរនេះមានន័យថាចៅ ក្រមទំនងជាកាត់អោយមានទោសតែករណី ដែលប្រព្រឹត្តិតាមបែបព្រៃផ្សៃតែប៉ុណ្ណោះ ។

មានបញ្ហាមួយចំនួនទៀតដែលទាក់ទិនទៅនឹងប្រព័ន្ធតុលាការ ដែលតែងតែពឹងផ្អែកទៅលើភស្តុតាងលិខិតកោសល្យវិច្ច័យ ។ បញ្ហាជាច្រើនរួមមានការធ្វើដំណើរ និងការចំណាយផ្សេងៗសំរាប់ជនរងគ្រោះ[៣២] ចំពោះករណី

---

[៣២] ចំពោះការពិភាក្សាថែមទៀតអំពីបញ្ហាការចំណាយលើលិខិតកោសល្យវិច្ច័យ សូមអានផ្នែក ៧ ខាងក្រោម ចំណងជើង គ ការពឹងផ្អែកទៅលើលិខិតកោសល្យវិច្ច័យ ។

ជនរងគ្រោះរស់នៅតំបន់ដាច់ស្រយាលគ្មានមន្ទីរពេទ្យ រួមជាមួយនឹងការពន្យាពេលក្នុងការរាយការណ៍ពីករណីរំលោភទៅអាជ្ញាធរដែលតែងតែកើតឡើងជារឿយៗ ។ កត្តាទាំងអស់នេះ អាចបណ្តាលអោយមានការពន្យាពេលក្នុងដំណើរការធ្វើកោសល្យវិច្ច័យ ហើយពន្យារហូតដល់ហួសពេលដែលមិនអាចធ្វើកោសល្យវិច្ច័យបាន ។ ជាលទ្ធផលករណីដែលលីកាដូស៊ើបអង្កេតទាំងឡាយមានតែ១៩% ប៉ុណ្ណោះដែលអាចមានលិខិតកោសល្យវិច្ច័យនៅក្នុងឆ្នាំ ២០០២ ហើយមានត្រឹមតែ ១១% ប៉ុណ្ណោះកាលពីឆ្នាំ ២០០៣ កន្លងទៅនេះ ។

## គ. តុលាការកម្ពុជាអាច និងត្រូវតែជំនះឧបសគ្គទាំងនេះ

ការជំនះនាំងឧបសគ្គទាំងនេះ ភាពស្មុគស្មាញ និងការលំបាកនានាក្នុងករណីរំលោភ និងករណីបៀតបៀនកេរ្តិ៍ខ្មាស់បង្ហាញនូវសារសំខាន់យ៉ាងធំធេង ប៉ុន្តែមិនដែលយកជ័យជំនះលើឧបសគ្គទាំងនេះបាននៅក្នុងតុលាការកម្ពុជាទេ ។ តុលាការអាចផ្តន្ទាទោសជនល្មើសក្នុងបទល្មើសរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់យ៉ាងត្រឹមត្រូវ ដើម្បីបង្ហាញអោយសមាជិកគ្រួសារបានឃើញនូវការនុវត្តន៍របស់តុលាការចំពោះបទល្មើសរំលោភផ្លូវភេទ ។ នៅឆ្នាំ២០០២ កន្លងទៅអង្គការលីកាដូបានប្រមូលចងក្រងឯកសារករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ចំនួន ២៣ករណី ដែលប្រព្រឹត្តិដោយឪពុក ឪពុកចុង ជីដូនមួយ ឬញាតិសន្តានផ្សេងៗទៀត[៣៣] ។ ក្នុងចំណោមករណីទាំងនោះ មានជនជាប់ចោទ ១៤នាក់ក្នុងចំណោមជនជាប់ចោទចំនួន ២៣នាក់ ត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារពី ២ឆ្នាំទៅ ២០ឆ្នាំ ។ ចំនួនអត្រា៦០% នៃការវិនិច្ឆ័យទោសចំពោះករណីពាក់ព័ន្ធនឹងសមាជិកគ្រួសារ ដែលត្រូវបានរាយការណ៍ថាមានកំរិតខ្ពស់ជាងបីដងបើធៀបទៅនឹងករណី ដែលបានផ្តន្ទាទោសដូចគ្នាដែលប្រព្រឹត្តិដោយជនល្មើសជាអ្នកដ៏ទៃដែលពុំមែនជាសាច់ញាតិរបស់ជនរងគ្រោះ ។

នៅឆ្នាំ ២០០៣ លីកាដូបានចងក្រងជាឯកសារនូវករណីរំលោភសេពសន្ថវៈ ឬរំលោភផ្លូវភេទចំនួន ១៣ករណីដែលជនល្មើសជាឪពុក ឬឪពុកចុង[៣៤] ។ ករណីមួយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយះពេល ១៥ឆ្នាំ ។ មានករណីមួយទៀតត្រូវបានដោះស្រាយដោយខុសច្បាប់ក្រៅប្រព័ន្ធយុត្តាធិការ ។ រីឯករណីមួយទៀតនៅកំពុងរង់ចាំដំណើរការក្តីនៅឡើយ ។

ទាំងនេះអាចនិយាយបានថាករណីរំលោភសេពសន្ថវៈដែលប្រព្រឹត្តិដោយសមាជិកគ្រួសារប្រហែលជាអាចត្រូវបានមើលងាយជាពិសេសពីសំណាក់ប្រព័ន្ធតុលាការ ។

---

[៣៣] បទល្មើសខាងផ្លូវភេទដែលប្រព្រឹត្តិដោយគ្រួសារបានបន្តឡើងដល់ ១៣% ក្នុងចំណោមករណីទាំងអស់រាយការណ៍មកលីកាដូក្នុង ឆ្នាំ ២០០២ ។

[៣៤] បទល្មើសខាងផ្លូវភេទដែលប្រព្រឹត្តិឪពុក /ឪពុកចុងរបស់ជនរងគ្រោះមាន ៧% នៃករណីទាំងឡាយដែល លីកាដូស៊ើបអង្កេតក្នុងឆ្នាំ ២០០៣ ។

## ៤. ករណីសិក្សាចំពោះការបកស្រាយច្បាប់ដោយមិនសមហេតុផល

តាមច្បាប់រដ្ឋធម្មនុញ្ញប្រព័ន្ធតុលាការកម្ពុជាមានការតព្វកិច្ច ដើម្បីការពារប្រជាពលរដ្ឋកម្ពុជាទូទៅ ។ នៅក្នុងបរិបទនៃករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ កាតព្វកិច្ចគួរតែត្រូវបានយកមកអនុវត្តខ្លះៗនៅក្នុងការស៊ើបអង្កេតរកការពិត ដើម្បីយកមកវិភាគអោយបានត្រឹមត្រូវនូវធាតុផ្សំទាំងឡាយរបស់បទឧក្រិដ្ឋ ហើយបកស្រាយអោយបានសមរម្យនូវមាត្រាច្បាប់ពាក់ព័ន្ធនានា និងអនុវត្តន៍ច្បាប់ដោយឥតលំអៀងទៅតាមអង្គហេតុសំណុំរឿង[៣៥] ។ តែជាការគួរអោយស្តាយ ដែលតុលាការកម្ពុជាបានបង្ហាញនូវនិន្នាការមួយ ដែលធ្វេសប្រហែសចំពោះទិដ្ឋភាពនៃអំពើរំលោភផ្លូវភេទខ្លះៗ ទោះបីជាទិដ្ឋភាពទាំងនោះមិនបានបង្កើតជាធាតុផ្សំនៃបទល្មើសក៏ដោយ ក៏វាមានឥទ្ធិពលជះមកលើការវិភាគច្បាប់របស់តុលាការដែរ ។

### ក. កំរិតជំរៅនៃការរំលោភសេពសន្ថវៈ និងការបាត់បង់នូវព្រហ្មចារី

**ករណីសិក្សាទី ១ : កំរិតជំរៅនៃការរំលោភសេពសន្ថវៈ និងការបាត់បង់នូវព្រហ្មចារី**[៣៦]

អេង សុខា ត្រូវបានចោទប្រកាន់ពីបទរំលោភកុមារី អាយុ ៦ឆ្នាំ ហើយត្រូវនាំខ្លួនមកចំពោះមុខចៅក្រមជំនុំជំរះក្តី គង់ គួយ ។ ឆ្មបម្នាក់បានបញ្ជាក់ថា ជនរងគ្រោះ ត្រូវបានរំលោភ។ នៅក្នុងសវនាការកាលពីខែ មករា ឆ្នាំ២០០០ គាត់បានលើកហេតុផលថា "**ករណីរំលោភនេះមិនដល់ទីជំរៅទេ**" រីឯ "**ព្រហ្មចារីរបស់ កុមារីក៏នៅល្អ នៅឡើយ**" ចៅក្រម គង់ គួយ ក៏បានប្តូរបទចោទមកជាទង្វើបៀតបៀនកេរ្តិ៍ខ្មាស់វិញ ហើយកាត់ទោសអោយជាប់ពន្ធនាគាររយៈពេល ៦ខែ និងព្យួរទោស ៦ខែទៀត ដោយស្របពេលជាមួយនឹងពេលវេលាដែលជនល្មើសបានបំរើក្នុងពន្ធនាគារជិតដល់ពេលបញ្ចប់ទៅហើយ ។ ជនល្មើសនោះត្រូវបានដោះលែងអោយនៅក្រៅពន្ធនាគារនៅក្នុងអំឡុងពេលដែលត្រូវសល់ពេលមួយខែត្រូវជាប់ឃុំឃាំងទៀត ។

នៅខែឧសភា ឆ្នាំ ២០០២ ជនល្មើសដដែលនេះត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងរំលោភកុមារីអាយុ ៧ឆ្នាំ។ ចៅក្រម គង់ គួយ ត្រូវបានចាត់អោយកាន់ក្តីម្តងទៀត តែពេលនេះគាត់ជាចៅក្រមស៊ើបអង្កេត ។ សារជាថ្មីក្តី គាត់បានបន្ថយមកនៅត្រឹមបទបៀតបៀនកេរ្តិ៍ខ្មាស់ទៀត គាត់រាយការណ៍ប្រាប់កាសែតភ្នំពេញប៉ុស្តិ៍ថា" គាត់មិនទាន់បានធ្វើអ្វីធ្ងន់ធ្ងរមកលើកុមារីផង គាត់គ្រាន់តែប៉ះនាងពីខាងក្រៅតែប៉ុណ្ណោះ ហើយមិនដល់ទីជំរៅទេ"[៣៧] ។ ប៉ុន្តែ ចៅក្រមជំនុំជំរះ ខ្លួត ពេជ្រ បានទទួលយកសំណើរបស់ព្រះរាជអាជ្ញាដោយចោទប្រកាន់ពីបទរំលោភសេពសន្ថវៈដដែល។

---

[៣៥] សូមអានសៀវភៅក្បួនរបស់តុលាការ ខាងលើចំណុចទី ៩ ទំព័រ ១១៨-១១៩ ។

[៣៦] អង្គហេតុនៃករណីនេះក៏ត្រូវបានរាយការណ៍ដោយ Bill Brainbridge និងលន់ ណារ៉ា " ស៊េរីជនល្មើស ដែលត្រូវបញ្ជូនវិលមកតុលាការវិញក្រោមការចោទថ្មីមួយទៀតពីបទប៉ុនប៉ងរំលោភក្មេងស្រីម្នាក់ផ្សេងទៀត " ភ្នំពេញប៉ុស្តិ៍ លេខ ១១/១១ ថ្ងៃទី ២៤ ឧសភា - ៦ មិថុនា ២០០២ ។

[៣៧] ភ្នំពេញប៉ុស្តិ៍ លេខ ១១/១១ ថ្ងៃទី ២៤ ឧសភា - ៦ មិថុនា ២០០២ ។

- **ការបកស្រាយមាត្រាច្បាប់តាមគតិយុត្តិ**

យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីការដាក់ស្ថានទំងន់ទោសនៃបទឧក្រិដ្ឋក្នុងឆ្នាំ ២០០១ បានកំណត់និយមន័យនៃពាក្យរំលោភសេពសន្ថវៈថា "គឺរាល់គ្រប់អំពើបញ្ចូលអង្គជាតភេទ ឬមធ្យោបាយផ្សេងទៀតដោយឃោឃៅ ដោយបង្ខំ ឬ ដោយមិនអោយដឹងខ្លួនជាមុន" ទំហំកិរិតនៃការរំលោភបំពានមិនបានបញ្ជាក់ទេ ហើយចៅក្រមមិនគួរលើកមកពិចារណានូវចំណុចបែបនេះដែរ ។ កិរិតនៃការបំពានណាមួយក៏ដោយក៏នឹងអាចសមតាមនិយមន័យនៃពាក្យរំលោភសេពសន្ថវៈនេះបានដែរ ។

លើសពីនេះទៅទៀតមាត្រាច្បាប់ចែងថា "ជននោះដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភនឹងបានចោទប្រកាន់ពីបទរំលោភ" ។ ថ្វីបើ ជនដែលមិនបានបញ្ចូនអង្គជាតមកលើជនរងគ្រោះ ក្តីក៏ត្រូវមានទោសដូចបទរំលោភសេពសន្ថវៈដែរ ប្រសិនបើមានភស្តុតាងបញ្ជាក់ថាជននោះមានចេតនាបំពានលើជនរងគ្រោះជាក់ស្តែង ។ កង្វះសកម្មភាពបញ្ចូលអង្គជាតពុំមែនមានន័យថាបទល្មើសអាចបន្ធូបន្ថយមកនៅបទព្រហ្មទណ្ឌកិរិតស្រាល ដោយចោទពីប្រកាន់ពីបទបៀតបៀនកេរ្តិ៍ខ្មាស់បាននោះទេ ។ ចៅក្រមស៊ើបអង្កេតអាចបន្ថយបទចោទប្រកាន់ដោយស្របច្បាប់នៅពេលដែលការស៊ើបអង្កេតមិនបានបង្ហាញនូវភស្តុតាងគ្រប់គ្រាន់ ដើម្បីបង្គ្រប់ការចោទប្រកាន់ពីខាងដើមបានដោយយោងទៅតាមការពិនិត្យមាត្រាច្បាប់នោះយ៉ាងហ្មត់ ចត់បំផុត[៣៨] ។

ហេតុផលរបស់ចៅក្រម គង់ គួយ ក្នុងការបន្ថយបទចោទពីរំលោភសេពសន្ថវៈ មកជាអំពើបៀតបៀនកេរ្តិ៍ខ្មាស់វិញនោះជាការមិនត្រឹមត្រូវទេ ។ ចំណុចទីមួយ កិរិតទីជំរៅនៃការបញ្ចូលអង្គជាតពុំមែនជាធាតុផ្សំនៃបទល្មើសទេ ហើយក៏មិនត្រូវប្តូរបទចោទប្រកាន់បទល្មើសដែរ ។ ចំណុចទីពីរ ការចោទប្រកាន់អាចត្រូវបានបន្ថយនៅពេលណាដែលគ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការចោទពីខាងដើមតែប៉ុណ្ណោះ ហើយក្នុងករណីនេះការផ្តល់កស្សិណសាក្សីរបស់ពេទ្យឆ្មបបានបញ្ជាក់អំពីបទរំលោភផ្លូវភេទរួចមកហើយ ។

- **ការបាត់បង់ព្រហ្មចារី**

ករណីសិក្សាក៏បានបង្ហាញនូវជំនឿដែលជឿខុសផងដែរ ដោយគេយល់ថាបទរំលោភអាចចាត់ទុកជាករណីធ្ងន់ធ្ងរបានលុះត្រាតែបាត់បង់ព្រហ្មចារី (រហែកក្រដាសព្រហ្មចារី) ទោះបីជា មានការរំលោភបំពានក៏ដោយ ហើយទោះបីជាបទល្មើសត្រូវបានប្រព្រឹត្តិទៅលើកុមារីដ៏វ័យក្មេងជាទីបំផុតក៏ដោយ ។ ក្នុងករណីនេះ យើងអាចទាយទុកជាមុនថាក្រមព្រហ្មទណ្ឌថ្មី នៅពេលពិភាក្សា និងមុនពេលអនុម័តត្រូវតែមានការបកស្រាយបំភ្លឺនូវគំនិតទំហំកិរិត និងប្រភេទនៃសកម្មភាពដាក់បញ្ចូលអង្គជាត ដែលបង្កើតបានជាបទល្មើសរំលោភសេពសន្ថវៈ[៣៩] ។ រហូតមកដល់ពេលនោះ ចៅក្រម ទាំងឡាយត្រូវបានទាមទារអោយអនុវត្តច្បាប់អោយបានហ្មត់ចត់ ហើយមិនត្រូវយកធាតុណាមករាប់បញ្ចូលនៅក្នុងបទល្មើសមួយផ្សេងទៀតឡើយ ។

---

[៣៨] គំរោងជំនួយយុត្តិធម៌ ព្រហ្មទណ្ឌកម្ពុជា" សៀវភៅក្បួនតុលាការ (USAID កម្ពុជា ឆ្នាំ ១៩៩៩) ទំព័រ ៦៥ ។

[៣៩] មាត្រា ២៩៩ នៃពង្រាងក្រមព្រហ្មទណ្ឌ (ខែកញ្ញា ឆ្នាំ ២០០០ ដឹកនាំដោយលោក ភីលីព ខាសតែល) ។

## ១. ទំនាក់ទំនងរវាងជនរងគ្រោះ និងជនល្មើស

**ករណីសិក្សាទី ២: ទំនាក់ទំនងរវាងជនរងគ្រោះនិងជនល្មើស**

កាលពីខែ ឧសភា ឆ្នាំ ២០០៣ នៅពេលដែលអង្គការលីកាដូបានសំភាសន៍ ជាមួយក្រឡាបញ្ជីតុលាការក្រុងភ្នំពេញម្នាក់ គាត់បានបង្ហាញនូវទស្សនៈមួយថា ប្រសិនបើបុរស និងស្ត្រីមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក ហើយជនជាបុរសបានរំលោភនារីនោះ (ទោះបីជាជនល្មើសបានបង្ករអំពើហិង្សា ថែមពីលើនេះទៀតក៏ដោយ) ក៏នៅតែមិនចាត់ទុកថាជាករណីរំលោភសេពសន្ថវៈដែរ ។ ការលើកឡើងពីការអនុវត្តន៏ជាប្រចាំរបស់ក្រឡាបញ្ជីតុលាការក្នុងប្រព័ន្ធតុលាការ ដូចពុំនោលនេះ គឺបង្ហាញនូវក្តីបារម្ភចំពោះការយល់ខុស ដែលបានបញ្ជាក់យ៉ាងច្បាស់លាស់ ហើយអាចនាំទៅរកផលវិបាកជា អវិជ្ជមានដល់ជនរងគ្រោះដោយអំពើរំលោភផ្លូវភេទ ។

- **ការបកស្រាយត្រឹមត្រូវ**

យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីការដាក់ស្ថានទំងន់នៃបទឧក្រិដ្ឋក្នុងឆ្នាំ ២០០១បានកំណត់និយមន័យថា "បទរំលោភសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាត ឬមធ្យោបាយផ្សេងទៀត ដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន[៤០] ។

ប្រសិនបើការរំលោភសេពសន្ថវៈបានប្រព្រឹត្តឡើង ដោយការគំរាមកំហែងដោយអាវុធ ទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬជនមានសតិវិបល្លាស ឬពិការរាងកាយ ឬលើអនីតិជន អាយុតិចជាង១៤ឆ្នាំ ធ្វើឡើងដោយមានអ្នកប្រព្រឹត្តមួយនាក់ ឬច្រើននាក់ ឬដោយមានអ្នកសមគំនិត ឬបើការសេពសន្ថវៈត្រូវប្រព្រឹតឡើងដោយជនដែលមានអំណាចលើអ្នករងគ្រោះ ទណ្ឌកម្មដែលត្រូវអនុវត្ត គឺដាក់ពន្ធនាគារតម្រូវអោយធ្វើការធ្ងន់ពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ[៤១] ។

ក្រឡាបញ្ជីក៏បានបកស្រាយធាតុផ្សំបទល្មើសខុសលើពីរចំណុចផងដែរ ។ ចំណុចទីមួយ ទំនាក់ទំនងដែលមានស្រាប់មិនអាចច្រានចំណុចការយល់ព្រម ឬបទឧក្រិដ្ឋដោយបង្ខំចេញបានឡើយ ។ ការបង្ខំអោយស្ត្រីមានទំនាក់ទំនងផ្លូវភេទដោយពុំមានការយល់ព្រមពីនាងនោះ គឺពិតជាការរំលោភបំពានផ្លូវភេទ ។ ចំណុចទីពីរការប្រព្រឹត្តិអំពើហិង្សាបន្ថែមគឺពុំមែនជាធាតុដ៏សំខាន់នៃបទល្មើសរំលោភទេ ។ ភាសាខ្មែរពាក្យថា "ការបង្ខំ" មិនបានបញ្ជាក់ថាការបង្ខំ ដោយកំលាំងបាយឡើយ ប៉ុន្តែវាសំដៅទៅលើ "គ្មានការយល់ព្រម" ផងដែរ ។ ទោះជាយ៉ាងនេះក្តីអំពើហិង្សាគឺជាកត្តាធ្ងន់ធ្ងរមួយដែលគួរត្រូវលើកយកមកពិចារណាពេលបើកសវនាការក្តីសំណុំរឿងនេះ ដោយប្តូរការកំណត់ទោសពី ១០-១៥ឆ្នាំ ទៅជា ១៥-២០ឆ្នាំ វិញព្រមទាំងបង្ខំអោយធ្វើពលកម្មថែមទៀត[៤២] ។

---

[៤០] រដ្ឋធម្មនុញ្ញ -មាត្រា ៣១ ។

[៤១] មាត្រា ៥ នៃច្បាប់ស្តីពីការដាក់ស្ថានទំនង់ទោសនៃបទបទឧក្រិដ្ឋ ។

[៤២] មាត្រា ៥ នៃច្បាប់ដដែល ។

ហេតុផលដូចគ្នានេះនឹងត្រូវយកមកអនុវត្តនៅក្នុងករណីដែលជនរងគ្រោះ និងជនល្មើសដែលត្រូវចាប់អោយរៀបការផងដែរ ច្បាប់អនុវត្តដូចគ្នាចំពោះមនុស្សគ្រប់រូបដោយមិនគិតពីស្ថានភាពក្នុងចំណងអាពាហ៍ពិពាហ៍ឡើយ[៤៣] ។

## គ. ការបញ្ចេញទឹកកាម

**<u>ករណីសិក្សាទី ៣:</u> ការចេញទឹកកាម**

ក្រឡាបញ្ជីតុលាការក្រុងដដែលនោះ ដូចក្នុងករណីសិក្សាទី ២ បាននិយាយប្រាប់ លីកាដូថាវាជាការមួយ ដែលយើងអាចទទួលយកបានក្នុងការកាត់បន្ថយនូវរយៈពេលជាប់ពន្ធនាគារ បើករណីរំលោភសេពសន្ថវៈនោះមិនទាន់បានចេញទឹកកាមទេ ទោះបីជាករណីរំលោភនោះមានប្រើហិង្សាក៏ដោយ ។ ក្រឡាបញ្ជីនោះបានសើចនៅកណ្តាលវាលក្នុងខណៈនិយាយហេតុការដូច្នេះប្រាប់បុគ្គលិកលីកាដូពីករណីមួយ ដែលបុរសវ័យចំណាស់អាយុ ៦០ឆ្នាំម្នាក់ព្យាយាមរំលោភកុមារីម្នាក់ ប៉ុន្តែប្រដាប់ភេទរបស់គាត់មិនឡើងរឹងសោះ ហើយក៏មិនចេញទឹកកាមផងដែរ ។ តាមសំដីក្រឡាបញ្ជីនោះ ករណីនេះគាត់ថាពុំមែនជាករណីរំលោភសេពសន្ថវៈ ទេ ។

- **ការបកស្រាយត្រឹមត្រូវ**

យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីការដាក់ស្ថានទំងន់នៃបទល្មើសឧក្រិដ្ឋក្នុងឆ្នាំ បានចែងថា រំលោភសេពសន្ថវៈ និងប៉ុនប៉ងរំលោភគឺជាបទឧក្រិដ្ឋដូចគ្នា ។ ដើម្បីកំណត់ទោសចំពោះបទល្មើសរំលោភនេះ (រំលោភឬប៉ុនប៉ងរំលោភក្តី) ការវិនិច្ឆ័យទោសត្រូវកំណត់ច្បាស់ថា ជនល្មើសពិតជាបានប្រព្រឹត្តិអំពើនេះមែន ហើយជនល្មើសថែមទាំងមានចេតនាក្នុងការប្រព្រឹត្តិទៀតផង[៤៤] ។ ប្រសិនបើធាតុផ្សំទាំងនេះត្រូវបានកំណត់ហួសចំណុចសង្ស័យដែលមានលក្ខណៈសមហេតុផលនោះ តុលាការនឹងកំណត់ថាជនជាប់ចោទនោះមានទោសមែន ។

ប្រការដែលជនល្មើសអសមត្ថភាពក្នុងការបញ្ចេញទឹកកាមមិនប៉ះពាល់ដល់ការវិភាគទេ ប្រសិនបើវាត្រូវបានកំណត់ថា (ទី១) បានរំលោភ ឬប៉ុនប៉ងរំលោភជនរងគ្រោះ និង(ទី២) មានចេតនារំលោភជនរងគ្រោះ ។ ជាពិសេសចំណុចនេះសុំសង្វាក់ពាក់ព័ន្ធគ្នា ព្រោះអង្គការលីកាដូកត់សំគាល់ឃើញថាជនរងគ្រោះមួយចំនួនជាពិសេសកុមារត្រូវបានរំលោភដោយប្រើវត្ថុអ្វីមួយ ឬផ្នែកណាមួយនៃរាងកាយច្រើនជាងការរំលោភលើប្រដាប់ភេទរបស់ពួកគេដូចជាបើ ឈើ ដប ម្រាមដៃ និង/ឬដោយអណ្តាត ។

---

[៤៣] រដ្ឋធម្មនុញ្ញ មាត្រា ៣១ ។

[៤៤] សូមអានសៀវភៅក្បួនតុលាការបន្ថែម - ចំណុច ៥ ទំ. ១០១ ។

## ៥. ការរំលោភជាក្រុម

### ក. ការរំលោភជាក្រុម

លីកាដូបានស៊ើបអង្កេតលើពាក្យបណ្តឹងរំលោភសេពសន្ថវៈជាក្រុមចំនួន[៤៥] ៨ករណីក្នុងឆ្នាំ២០០២។ មានករណីមួយក្នុងចំណោមករណីទាំងអស់ ដែលជនល្មើសទាំង៣ត្រូវបានចោទប្រកាន់ និងបានផ្តន្ទាទោសជាប់ពន្ធនាគារ ១៨ឆ្នាំ ព្រមទាំងបញ្ជាអោយសងជំងឺចិត្តជនរងគ្រោះទៀតផង ។ បណ្តឹងមួយទៀតត្រូវបានដោះស្រាយក្រៅប្រព័ន្ធតុលាការ ។ ករណីដែលសេសសល់ទាំងប៉ុន្មានកំពុងរង់ចាំ ឬករណីខ្លះទៀតត្រូវបានលើកលែងការចោទប្រកាន់ ។

នៅក្នុងឆ្នាំ ២០០៣ លីកាដូបានស៊ើបអង្កេតករណីរំលោភជាក្រុមចំនួន ១១ករណី ក្នុងនោះមាន ៤ករណីត្រូវបាន ឈានដល់ការកាត់ក្តី មានតែ១ករណីត្រូវបានផ្តន្ទាទោសជនល្មើស ២នាក់ ដាក់ពន្ធនាគារ ១២ឆ្នាំ និងមាន ២ករណីទៀតត្រូវបានដោះស្រាយក្រៅប្រព័ន្ធយុត្តាធិកា ហើយ ៥ករណីផ្សេងទៀតរង់ចាំដំណើរការក្តី[៤៦] ។

ពត៌មានដែលលីកាដូទទួលបានមិនបានបញ្ជាក់ថាជនរងគ្រោះនៃការរំលោភសេពសន្ថវៈជាក្រុមនេះ សុទ្ធជាស្ត្រីបំរើផ្លូវភេទទេ ។ អត្ថបទកាសែតមួយដែលរាយការណ៍កាលពីពេលថ្មីៗនេះដោយកាសែតឃែមបូឌៀដេលីថា "អំពើរំលោភផ្លូវភេទជាក្រុមលើស្ត្រីរកស៊ីបំរើផ្លូវភេទនោះ គឺជាបាតុភាពមួយដែលប្រព្រឹត្តឡើងអោយមានការរន្ធត់ តក់ស្លុតយ៉ាងខ្លាំង ហើយការបញ្ជាក់នេះហាក់ដូចមានការកើនឡើងនៅរាជធានីភ្នំពេញ[៤៧]" ។ អត្ថបទកាសែតនោះបានផ្អែកទៅលើការស្រាវជ្រាវមួយដែលអនុវត្តដោយអង្គការយេនឌ័រ និងការអភិវឌ្ឍន៍កម្ពុជា GAD[៤៨] ។ ការសិក្សាស្រាវជ្រាវរបស់ GAD បានអោយដឹងថា ការរំលោភផ្លូវភេទជាក្រុមកម្រនឹងត្រូវបានផ្តន្ទាទោសណាស់នៅកម្ពុជា ដោយហេតុថាជនរងគ្រោះភាគច្រើនជាអ្នកប្រកបរបរបំរើផ្លូវភេទ ។

មនុស្សគ្រប់រូប ដោយមិនគិតពីជំនាញ វិជ្ជាជីវៈ ជនជាតិ ឬស្ថានភាពអ្វីមួយឡើយ ត្រូវតែទទួលបានសិទ្ធិការពារសន្តិសុខជាមូលដ្ឋាន និងការធានាការការពារសិទ្ធិដោយរដ្ឋធម្មនុញ្ញស្មើៗគ្នានៅចំពោះមុខច្បាប់ ។ តុលាការកម្ពុជាមានភារកិច្ច ដើម្បីធានាដល់ពលរដ្ឋកម្ពុជាគ្រប់រូប មិនថាជននោះជាស្ត្រីរកស៊ីបំរើផ្លូវភេទក្តីក៏ត្រូវទទួលបានដោយគ្មានការរើសអើងយ៉ាងពេញលេញពីសមត្ថកិច្ចនៃច្បាប់ ។

---

[៤៥] ចំពោះគោលបំណងនៃរបាយការណ៍នេះ "ការរំលោភផ្លូវភេទជាក្រុម " គឺមានជនល្មើសចាប់ពី ២នាក់ឡើងទៅ ។

[៤៦] "សំណុំរឿងរង់ចាំ" មានន័យថាករណីទាំងនោះកំពុងដំណើរការនៅតុលាការ -កំពុងស៊ើបអង្កេត ឬមិនទាន់មានការចាត់វិធានការណាមួយនៅឡើយ ។ លីកាដូធ្លាប់សង្កេតឃើញថា ករណីជាច្រើនដែលរង់ចាំនោះកម្រឈានដល់ការកាត់ក្តីណាស់ ។

[៤៧] ឃេវិន ដូយ និង យុន សាមែន - យុវជនបច្ចុប្បន្ន "ការរំលោភផ្លូវភេទជាក្រុមបានក្លាយជាកីឡាមួយរបស់យុវជនសម័យថ្មី ។" ឌឹឃែមបូឌាដេលី ១៩-២០ ២០០៣ ទំព័រ. ៦ "យុវជនបច្ចុប្បន្ន" ។

[៤៨] GAD Paupers and Princelings: ឥរិយាបទរបស់យុវជនចំពោះក្រុមបងធំ អំពើហិង្សារំលោភផ្លូវភេទ គ្រឿងញៀន និងចោរកម្ម" ។ GAD ផ្អែកលើរបាយការណ៍ស្រាវជ្រាវរបស់ខ្លួនដែលសំភាសន៍យុវជនចំនួន ៥៨០ នាក់ មាន អាយុពី ១៣-២៨ ឆ្នាំ ក្នុងសង្កាត់ចំនួន ២៤ នៅភ្នំពេញ ។

## ខ.ទារុណកម្ម និងសកម្មភាពហិង្សាបន្ថែមដទៃទៀត

លីកាដូបានផ្តល់ការជួយឧបត្ថមដល់ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈចំនួន ៧នាក់ ដែលត្រូវការព្យាបាលដោយសារការរងរបួសនៅឆ្នាំ ២០០២ និង ៥នាក់ទៀត នៅឆ្នាំ២០០៣ ។ នៅក្នុងកម្មវិធីប្រឆាំងនឹងទារុណ្ឋកម្មរបស់លីកាដូ នាឆ្នាំ ២០០២ -២០០៣ បានផ្តល់សេវាស្តារលទ្ធភាពរយៈពេលយូរអង្វែងដល់ជនរងគ្រោះចំនួន ២នាក់ ដែលត្រូវបានរងពីការរំលោភផ្លូវភេទនៅក្នុងកំឡុងពេលដូចគ្នា ។ ករណីទាំង ២ នោះពាក់ព័ន្ធនឹងកុមារី ម្នាក់អាយុទើបតែ ៤ឆ្នាំ ។ សេវាបំរើរួមមានការពិគ្រោះបញ្ហាជនរងគ្រោះ និងជាមួយសមាជិកគ្រួសារ ការព្យាបាលជំងឺ និងការពិនិត្យតាមដាន ថែទាំ ព្រមទាំងការផ្តល់នូវម្ហូបអាហារក្នុងរយៈពេលខ្លីសំរាប់តំរូវការចាំបាច់ ។

នៅក្នុងឆ្នាំ២០០២ លីកាដូបានស៊ើបអង្កេតករណីរំលោភសេពសន្ថវៈចំនួន ១១ករណីដែលបានសំលាប់ជនរងគ្រោះ ក្នុងនោះជនរងគ្រោះ ៩នាក់ មានអាយុក្រោម ១៨ឆ្នាំ ។ នៅឆ្នាំ ២០០៣ លីកាដូបានស៊ើបអង្កេតករណីរំលោភសេពសន្ថវៈចំនួន ៦ករណីដែលត្រូវរំលោភហើយសំលាប់ជនរងគ្រោះ -ក្នុងនោះជនរងគ្រោះ ៣នាក់ មានអាយុក្រោម ១៨ ឆ្នាំ។

## ៦. ការសម្រុះសម្រួលដោះស្រាយសងជំងឺចិត្តក្រៅផ្លូវច្បាប់ដោយមន្ត្រីពាក់ព័ន្ធ

នៅពេលដែលបញ្ហាព្រហ្មទណ្ឌបានកើតឡើង ការដោះស្រាយណាមួយខាងក្រៅប្រព័ន្ធតុលាការដើម្បីបញ្ចប់ការផ្តន្ទាទោសនោះ គឺជាអំពើខុសច្បាប់ទាំងស្រុង[៤៩] ។ ដំណោះស្រាយដ៏វែងអន្លាយ ប៉ុន្តែខុសច្បាប់ដោយបង្ខំជនរងគ្រោះអោយទទួលយកការសម្រុះសម្រួល ។ ជាធម្មតាជនរងគ្រោះត្រូវបានគេបង្ខំ ឬបញ្ចុះបញ្ចូលអោយបោះបង់នូវសិទ្ធិរបស់ពួកគេក្នុងការផ្តន្ទាទោសជនល្មើស ដើម្បីប្តូរយកការសងជំងឺចិត្តវិញ ។ អាស្រ័យដោយការគំរាមកំហែង ឬការលួងលោមបោកប្រាស់[៥០] ។ ការសម្រុះសម្រួលបែបនេះ អាចនឹងមានលក្ខណៈស្របច្បាប់ចំពោះការដោះស្រាយខាងក្រៅប្រព័ន្ធតុលាការនូវបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។ គេមិនគួរលួងលោមអោយទទួលការសងជំងឺចិត្ត ឬគំរាមបង្ខំនៅក្នុងបណ្តឹងព្រហ្មទណ្ឌបែបនេះឡើយ ។

### ក-ការសម្រុះសម្រួលដោះស្រាយសងជំងឺចិត្តដោយខុសច្បាប់ -ការអនុវត្តន៍ជាទូទៅ

ក្នុងចំណោមករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ដែលបានរាយការណ៍ មានករណីជាច្រើនត្រូវបានដោះស្រាយតាមរយៈការសម្រុះសម្រួលក្រៅប្រព័ន្ធតុលាការ ។ ក្នុងចំណោមករណីរំលោភសេពសន្ថវៈ ១៧៩ ដែលបានរាយការមកលីកាដូ ក្នុងឆ្នាំ ២០០២ មាន ៥៦ករណី (ស្មើនឹង ៣២%) ជាលទ្ធផលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ។ ក្នុងចំណោមករណីទាំង ១៧៩ មាន ៤០ករណី (ស្មើនឹង ២២%) ត្រូវបានដោះស្រាយក្រៅប្រព័ន្ធតុលាការ ។ ក្នុងចំណោមករណីរំលោភសេពសន្ថវៈ ១៧៧ករណី ដែលបានរាយការណ៍មកលីកាដូក្នុងឆ្នាំ ២០០៣ មាន ៤ករណី (ស្មើនឹង ២.៣%) ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ហើយករណីចំនួន ១៤ទៀត (ស្មើនឹង ៨%) ត្រូវបានដោះស្រាយមិនត្រឹមត្រូវតាមច្បាប់ ។

យោងតាមរបាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សរបស់អាដហុកឆ្នាំ ២០០២ ក្នុងចំណោមករណីរំលោភសេពសន្ថវៈចំនួន ២៩៧ករណី មានតែជនជាប់ចោទ ៤% ប៉ុណ្ណោះ ដែលត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារ[៥១] ។ តំណាងម្នាក់នៃអង្គការជំនួយផ្នែកច្បាប់កម្ពុជាបានធ្វើការប៉ាន់ប្រមាណថា មានករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ប្រហែលជា ៦០-៧០% ត្រូវបានដោះស្រាយនៅក្រៅប្រព័ន្ធតុលាការ ។

### ខ- ការសម្រុះសម្រួលដោះស្រាយសងជំងឺចិត្តជាអំពើប្រឆាំងនឹងច្បាប់

ការសម្រុះសម្រួលដោះស្រាយសងជំងឺចិត្តក្នុងករណីព្រហ្មទណ្ឌ គឺជាអំពើខុសច្បាប់ ព្រោះករណីព្រហ្មទណ្ឌ និងករណីរដ្ឋប្បវេណីមានភាពខុសគ្នាទាំងស្រុង ។ ដំណោះស្រាយបែបនេះអាចស្របច្បាប់តែករណីបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ដើម្បីជួសជុលការខូចខាត ។ តំរូវការដើម្បីបន្តករណីព្រហ្មទណ្ឌពុំត្រូវបានបញ្ចប់ដោយដំណោះស្រាយណាមួយ

[៤៩] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ-មាត្រា ៧ ៣៣ និង៥៥ ។

[៥០] ជំនួយផ្នែកច្បាប់កម្ពុជា ព្រឹត្តិប័ត្រប្រចាំត្រីមាស- លេខ ៥ (មិថុនា ២០០៣) ទំព័រ ២ ។

[៥១] របាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សរបស់អាដហុក ខែ កុម្ភៈ ឆ្នាំ ២០០៣ ទំព័រ ២៥ ។

ឡើយ ។ ហេតុនេះ រាល់ករណីរំលោភសេពសន្ថវៈ ឬបៀតបៀនកេរខ្មាស់ត្រូវតែបានបន្តទៀត ទោះបីជាមានសំណង រដ្ឋប្បវេណី ឬគ្មានក៏ដោយ ។

ជាពិសេស លីកាដូមានការខ្វាយខ្វល់យ៉ាងខ្លាំង ដែលមន្ត្រីអនុវត្តន៏ច្បាប់ទាំងឡាយ ដែលមានកាតព្វកិច្ចក្នុងការ លើកកំពស់ច្បាប់ និងការពារសាធារណៈជន បើពួកគេជាអ្នកដែលដើរតួក្នុងការសម្រុះសម្រួលដោះស្រាយសងសំណង រដ្ឋប្បវេណីខុសច្បាប់ទៅវិញ[៥២] ។ ជនរងគ្រោះត្រូវបានគេបង្ខំអោយទទួលយកនូវសំណងជាប្រាក់ ឬរឹតតែគួរអោយភ្ញាក់ ផ្អើលទៀត គឺបង្ខំអោយជនរងគ្រោះរៀបការជាមួយជនល្មើសជំនួសការផ្តន្ទាទោសនូវករណីរបស់គេ ឬបិទបាំងមុខមាត់ ក្រុមគ្រួសារគេ ។ មន្ត្រីដែលជួយសម្រុះសម្រួលជាធម្មតាបានដកហូតភាគរយពីចំនួនទឹកប្រាក់ដែលគេព្រមព្រៀងគ្នា នោះ ។ ទង្វើនេះគឺរឹតតែខុសច្បាប់ថែមទៀត ចំពោះមន្ត្រីណាដែលប្រព្រឹត្តិបែបនេះ ក្នុងនោះរួមមានមេភូមិ ដែលជាថ្នូរ នឹងការស្វែងរក ឬទទួលប្រាក់សំណងដែលជាលទ្ធផលនៃការរៀបចំវិធីដោះស្រាយនោះ ។

## គ . ជនរងគ្រោះដោយបទឧក្រិដ្ឋមានសិទ្ធិក្នុងការទាមទារជំងឺចិត្តតាមគតិច្បាប់

មាត្រា ២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌបានចែងថា រាល់បទល្មើសព្រហ្មទណ្ឌនឹងអាចមានបណ្តឹងពីរខុសគ្នា គឺ បណ្តឹងព្រហ្មទណ្ឌ និងបណ្តឹងរដ្ឋប្បវេណី[៥៣] ។ យោងតាមសៀវភៅមគ្គុទេសក៏ច្បាប់ព្រហ្មទណ្ឌកម្ពុជា[៥៤] ។

"បណ្តឹងរដ្ឋប្បវេណីដែលកើតឡើងដោយសារលទ្ធផលនៃការប្រព្រឹត្តិបទល្មើស គឺជាបណ្តឹងទាមទារសំណងជំងឺ ចិត្តដើម្បីជួសជុលការខូចខាតរបស់ជនរងគ្រោះ[៥៥] ។ ជនណាដែលជឿជាក់ថាខ្លួនរងរបួសដោយអំពីឧក្រិដ្ឋអាចធ្វើជា បណ្តឹងរដ្ឋប្បវេណី ដែលនឹងត្រូវបើកសវនាការជាគ្នានឹងការផ្តន្ទាទោសបទឧក្រិដ្ឋនៃបទល្មើសនោះ[៥៦] ឬនៅក្នុងបណ្តឹង រដ្ឋប្បវេណីផ្សេងគ្នានៅពេលដែលការផ្តន្ទាទោសបានចប់រួចហើយ[៥៧] " ។

នៅឆ្នាំ ២០០២ កន្លងទៅរំលោភសេពសន្ថវៈ ២៤ករណី ក្នុងចំណោម ៥៦ករណីដែលលីកាដូបានស៊ើបអង្កេត ហើយជាលទ្ធផលចុងក្រោយត្រូវផ្តន្ទាទោសទោសអោយជាប់ពន្ធនាគារ ជនល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ នោះ ក៏ត្រូវបញ្ជាអោយសងសំណងរដ្ឋប្បវេណីជាទឹកប្រាក់ផងដែរ ។ នៅឆ្នាំ ២០០៣ មាន ៣ករណីក្នុងចំណោមករណី ៤ ដែលចុងក្រោយត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ ជនល្មើសត្រូវបញ្ជាអោយសងសំណងរដ្ឋប្បវេណីផងដែរ ។ ប៉ុន្តែនៅ ពេលដែលជនល្មើសជាប់ឃុំឃាំង ហើយពួកគេកម្រសងសំណងរដ្ឋប្បវេណីទៅជនរងគ្រោះណាស់ ។

---

[៥២] មាត្រា ៧ ច្បាប់ស្តីនីតិវិធីព្រហ្មទណ្ឌ បណ្តឹងសាធារណៈ (ឧ.បញ្ហាព្រហ្មទណ្ឌ ) មិនអាចត្រូវបានដោះស្រាយតាមផ្លូវឯកជនក្រៅច្បាប់ឡើយ —សូមមើលខាង ក្រោមភាគទី ៥ ផ្នែក ខ ការសម្រុះសម្រួលដោះស្រាយសងជំងឺចិត្តជាទង្វើខុសច្បាប់ ។

[៥៣] ចំពោះបទបញ្ញត្តិដែលទាក់ទងនឹងបណ្តឹងព្រហ្មទណ្ឌ និងបណ្តឹងរដ្ឋប្បវេណី សូមអានច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ២ -៥-៦-៩ ១០-១២-១៩-៣៣- និង ៥៤ ។ អានសៀវភៅក្បួនតុលាការ ចំណុច ៩ ទំ. ១២២-១២៣ ។

[៥៤] មគ្គុទេសក៏ធនធាន ច្បាប់ព្រហ្មទណ្ឌកម្ពុជា ( ក្រុមអ្នកច្បាប់សិទ្ធិមនុស្សអន្តរជាតិ -កំរោងការពារក្តីកម្ពុជា ខែធ្នូ ឆ្នាំ ២០០០) ទំ. ៤៨ ។

[៥៥] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ -មាត្រា ៥ ។

[៥៦] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ -មាត្រា៩ ។

[៥៧] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ -មាត្រា ៦ ។

ក្នុងចំណោមមនុស្សទាំងអស់ដែលចូលរួមក្នុងការដោះស្រាយ ជនរងគ្រោះច្រើនតែជាអ្នកទទួលបានផលតិចតួចបំផុតពីការដោះស្រាយនោះ ។ ការដោះស្រាយបែបនេះ គឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗទាំងឡាយ ដែលជះឥទ្ធិពលមកលើដំណើរការផ្តន្ទាទោសសំណុំរឿងរំលោភសេពសន្ថវៈ និងការរំលោភផ្លូវភេទ ។ ការដោះស្រាយបែបនេះ គឺខុសច្បាប់ទាំងស្រុង ហើយថែមទាំងបានធ្វើអោយជនល្មើសជឿជាក់ថា គេអាចប្រព្រឹត្តអំពើអាក្រក់ដោយគ្មានទោសពៃរ៍អ្វីឡើយ និងជាការប្រាប់ដល់ជនរងគ្រោះថា ពួកគេមិនត្រូវបានទទួលការជួយជ្រោមជ្រែងពីសំណាក់ច្បាប់ឡើយ ហើយក៏មិនបានទទួលការការពារយ៉ាងពេញលេញពីសមត្ថកិច្ចច្បាបផងដែរ ។

## ៧. ហេតុអ្វីបានករណីរំលោភសេពសន្ថវៈមិនត្រូវបានរាយការណ៍ ឬក៏ត្រូវបានដោះស្រាយក្រៅប្រព័ន្ធតុលាការ

ករណីរំលោភសេពសន្ថវៈ និងករណីបៀតបៀនកេរ្តិ៍ខ្មាស់ ច្រើនតែមិនត្រូវបានរាយការណ៍នៅទូទាំងពិភពលោក ។ មានហេតុផលជាច្រើនដែលជនរងគ្រោះសំរេចមិនធ្វើពាក្យបណ្តឹង ។ នៅកម្ពុជាមានកត្តាច្រើនបន្ថែមទៀតដែលបណ្តាលអោយជនរងគ្រោះជំទាស់នឹងការរាយការណ៍ទៅអង្គភាពអនុវត្តច្បាប់នានា និងមន្ត្រីតុលាការ ។

### ក.និទ្ទណ្ឌភាព និងកង្វះទំនុកចិត្តនៅក្នុងប្រព័ន្ធយុត្តិធម៌

ជនល្មើសក្នុងករណីរំលោភសេពសន្ថវៈ និងផ្លូវភេទជាច្រើនជឿជាក់ថាពួកគេស្ថិត នៅពីលើច្បាប់ ហេតុដូច្នេះប្រសិនបើត្រូវបានចាប់ខ្លួន ទណ្ឌកម្មរបស់ពួកគេគឺគ្រាន់តែការសងជំងឺចិត្តតែប៉ុណ្ណោះ ។ និទ្ទណ្ឌភាពជាកត្តាធ្ងន់ធ្ងរណាស់ជាពិសេសនៅពេលដែលជនល្មើសជាអ្នកមានអំណាច ដូចជានគរបាល យោធា មន្ត្រីរាជការ អ្នកមានលុយកាក់/ទ្រព្យសម្បត្តិ ឬមនុស្សដែលពោពេញដោយអំណាច ។

គោលការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ គឺស៊ើបអង្កេតអំពើហិង្សាដែលប្រព្រឹត្តិដោយអ្នកមានតួនាទីក្នុងសមត្ថកិច្ចរដ្ឋ ដែលផ្តោតទៅលើអ្នកដែលបំរើការងារក្នុងជួររដ្ឋាភិបាល ។ ក្នុងចំណោម ២៨ករណីដែលបានរាយការណ៍មកលីកាដូ ក្នុងឆ្នាំ ២០០២ ដែលជនសង្ស័យត្រូវបានគេស្គាល់ថាជាមានតួនាទីក្នុងជួរមន្ត្រីរដ្ឋាភិបាល -ករណីចំនួន ៦ ត្រូវបានឈានដល់ការកាត់ទោស ដែលជាលទ្ធផលមានជនជាប់ចោទ៣នាក់ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ និង៣នាក់អោយរួចខ្លួន ។ ករណី ៨ ទៀតត្រូវបានដោះស្រាយក្រៅប្រព័ន្ធតុលាការ មាន ៦ករណីទៀត ដែលជនសង្ស័យបានគេចខ្លួន និង ៥ករណីទៀតជនសង្ស័យមិនត្រូវបានចាប់ខ្លួនទេ ។ ករណីនៅសល់ត្រូវរង់ចាំ ដំណើរការក្តី ។

ក្នុងឆ្នាំ ២០០៣ ក្នុងចំណោមករណីទាំង ២៥ ដែលបានរាយការណ៍និងស៊ើបអង្កេតដោយលីកាដូ គឺមានតែ ៥ ករណីប៉ុណ្ណោះដែលត្រូវបាននាំទៅប្តឹងដល់តុលាការ ហើយលទ្ធផលចុងក្រោយសំណុំរឿងទាំងនោះត្រូវបញ្ចប់ដោយគ្មាននរណាមានទោសទណ្ឌអ្វីឡើយ ។ មាន ៧ករណីត្រូវបានដោះស្រាយក្រៅប្រព័ន្ធតុលាការ។ ហើយករណីនៅសល់ទាំងអស់ត្រូវរង់ចាំដំណើរក្តីរបស់តុលាការ ។

លីកាដូកត់សំគាល់ឃើញថាភាគរយនៃការកាត់ទោសជនដែលជាមន្ត្រីរាជការក្នុងឆ្នាំ ២០០២-២០០៣ មានគំលាតទាបជាងការផ្តន្ទាទោសចំពោះជនសង្ស័យដែលមានឋានៈជាពលរដ្ឋសាមញ្ញខ្លាំងណាស់ ។ ចំណុចនេះហាក់ដូចជាបង្ហាញអោយឃើញថា មន្ត្រីរាជការបានទទួលផលចំណេញពីតួនាទី និងអំណាចរបស់ខ្លួនក្នុងបទល្មើសព្រហ្មទណ្ឌបែបនេះ ដែលជាការធ្វើអោយសាធារណៈជនបាត់បង់ជំនឿនៅក្នុងប្រព័ន្ធយុត្តិធម៌ ។

### ខ. អំពើពុករលួយ

ការផ្តន្ទាទោសចំពោះសំណុំរឿងបទឧក្រិដ្ឋ រដ្ឋជាអ្នកអនុវត្តក្នុងនាមជនរងគ្រោះកម្ពុជាទូទៅ ។ ដើមបណ្តឹងដែលធ្វើពាក្យបណ្តឹងមិនតំរូវអោយបង់ថ្លៃទេ ។ ប៉ុន្តែនៅក្នុងការអនុវត្តន៍ជាក់ស្តែង ដើមបណ្តឹងត្រូវបង់ប្រាក់អោយមន្ត្រីនានា ដើម្បីអោយក្តីរបស់ខ្លួនឈានដល់ការបើកសវនាការ ដោយចាប់ផ្តើមពីនគរបាលដើម្បីអោយពួកគេប្រមូលភស្តុតាង ហើយចុងក្រោយត្រូវបង់អោយបុគ្គលិកតុលាការដើម្បីដំណើរការងាររដ្ឋបាលក្នុងការផ្តន្ទាទោស ។ ការអនុវត្តន៍បែបនេះ គឺទង្វើខុសច្បាប់ ហើយមន្ត្រីកម្រចំណាយថវិកានេះលើការស៊ើបអង្កេតណាស់ ។ រឿងនេះវាក្លាយទៅជាទម្លាប់នៃការរកប្រភពចំណូលមួយសំរាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ដែលជាការចំណាយរបស់ជនរងគ្រោះ ។

ក្រឡាបញ្ជី និងចៅក្រមច្រើនតែពាក់ព័ន្ធទៅនឹងដំណោះស្រាយខុសច្បាប់ទាំងនេះ (ហើយជាចំណូលក្រាសក្រែលផង) ។ យុទ្ធសាស្ត្រមួយដើម្បីជីករំលើងអំពើពុករលួយនេះទាំងឫសនោះ គឺការតំឡើងប្រាក់បៀវត្សរ៍ដល់ក្រឡាបញ្ជីទាំងនេះ ដើម្បីកាត់បន្ថយការចូលរួមក្នុងសកម្មភាពពុករលួយទាំងនេះ ។ ប៉ុន្តែនេះពុំមែនមានន័យថា អំពើពុករលួយអាចទទួលយកបានទេក្នុងខណៈពេលដែលក្រឡាបញ្ជីរង់ចាំការតំឡើងប្រាក់បៀវត្សរ៍នោះ ។

## គ. ការពឹងផ្អែកតែលើលិខិតកោសល្យវិច្ច័យ

ក្នុងបច្ចុប្បន្ននេះ លិខិតកោសល្យវិច្ច័យ គឺជាធាតុផ្សំតែមួយគត់ដែលសំខាន់ជាងគេបំផុត ដើម្បីធ្វើការកាត់ទោសក្នុងករណីរំលោភសេពសន្ថវៈ ។ ការទទួលខុសត្រូវក្នុងការធ្វើការស៊ើបអង្កេត និងការចំណាយក្នុងការស៊ើបអង្កេត និងការផ្តន្ទាទោសបទល្មើសព្រហ្មទណ្ឌ គឺរដ្ឋជាអ្នកចេញចំណាយទាំងនេះ រួមទាំងការចំណាយសំរាប់ធ្វើកោសល្យវិច្ច័យ និងសាក្សីនានា ។ ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្តែងជនរងគ្រោះជាអ្នកចំណាយដើម្បីទទួលបានសំណុំភស្តុតាងដ៏សំខាន់មួយនេះ និងជំរុញអោយដំណើរការផ្តន្ទាទោសនោះអាចឈានទៅមុខទៀតបាន ។ មានជនរងគ្រោះជាច្រើនមិនមានលទ្ធភាពបន្តក្នុងរឿងក្តីព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីតទៅទៀតបានពីព្រោះបញ្ហាលើការចំណាយខុសប្រក្រតីដូចសព្វថ្ងៃនេះ ។ បញ្ហានេះបានដាក់អ្វីដែលហៅថា "យុត្តិធម៌" អោយរិតតែនៅឆ្ងាយពីអ្នកក្រថែមទៀត ។

## ៧-សេចក្តីសន្និដ្ឋាន

ការស៊ើបអង្កេត និងការប្រមូលឯកសារក្នុងករណីរំលោភសេពសន្ថវៈ និងករណីបៀតបៀនកេរ្តិ៍ខ្មាស់ ដែលអនុវត្តដោយលីកាដូក្នុងឆ្នាំ ២០០២-២០០៣ កន្លងទៅនេះបានបញ្ជាក់អោយឃើញនូវវិបត្តិនៃអំពើរំលោភសេពសន្ថវៈ និងបទល្មើសផ្លូវភេទនៅទូទាំងកម្ពុជា ។

គោលបំណងរបស់របាយការណ៍នេះ គឺដើម្បីបញ្ជាក់ពីការកើនឡើងនូវចំនួនករណីដែលបានរាយការណ៍ជនរងគ្រោះដែលមានអាយុទាបបំផុត និងដឹងថាមានជនរងគ្រោះជាច្រើនដែលកំពុងរងភាពអាម៉ាស់ តក់ស្លុត ភ័យខ្លាចខ្លាំងណាស់ ឬកំពុងតែមានជម្ងឺធ្លាក់ទឹកចិត្តយ៉ាងខ្លាំងជាមួយនឹងប្រព័ន្ធយុត្តិធម៌ក្នុងការរាយការណ៍ ឬដាក់ពាក្យប្តឹងនូវករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ ។ ពលរដ្ឋកម្ពុជាគ្រប់រូបមានសិទ្ធិដែលកំណត់ក្នុងច្បាប់រដ្ឋធម្មនុញ្ញពីភាពទទួលបាននូវយុត្តិធម៌ដ៏មានប្រសិទ្ធិភាព និងមានន័យខ្លឹមសារដោយគ្មានរងការភ័យខ្លាចពីការបំភិតបំភ័យ ឬរងអំពើពុករលួយឡើយ ។ អង្គការលីកាដូទាមទារអោយតុលាការកម្ពុជាអនុវត្ត និងបកស្រាយច្បាប់អោយបានត្រឹមត្រូវ និងប្រកបដោយមនះសិការស្របទៅនឹងភារកិច្ចរបស់ខ្លួន ។

ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនក្រៅរដ្ឋាភិបាលនានាដែលមានចំណែកនៅក្នុងកិច្ចការនេះមានតួនាទីយ៉ាងសំខាន់ ដើម្បីជំរឿន និងការពារសិទ្ធិមនុស្សក្នុងការជំរុញអោយមានការកែទំរង់ប្រព័ន្ធតុលាការ និងច្បាប់ដែលកំពុងត្រូវការយ៉ាងខ្លាំងនៅក្នុងសង្គមកម្ពុជា ។ សង្គមស៊ីវិលត្រូវស្គាល់ទាំងសិទ្ធិរបស់ខ្លួន និងមានជំនឿជឿជាក់គ្រប់គ្រាន់ក្នុងការអនុវត្តន៍ច្បាប់ព្រមទាំងប្រព័ន្ធតុលាការ ដើម្បីធ្វើបណ្តឹងករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ទាំងឡាយ ។ អង្គការមិនមែនរដ្ឋភិបាលត្រូវតែធ្វើការជំរឿនសិទ្ធិមនុស្សយ៉ាងសកម្មដល់ប្រជាពលរដ្ឋ និងធ្វើការជាមួយស្ថាប័នច្បាប់នានា ដើម្បីសំរេចបាននូវគោលដៅទាំងនេះ ។ ដំណោះស្រាយក្រៅតុលាការប្រព័ន្ធយុត្តាធិការពុំបានបំរើអោយទាំងជនរងគ្រោះ និងសង្គមកម្ពុជាទេ ។

ករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ គឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរ ជាពិសេសនៅពេលការដែលប្រព្រឹត្តិនោះលើកុមារ ។ ជាការពិតណាស់ ដែលព្រឹត្តិការណ៍ដ៏តក់ស្លុតដូចជាការរំលោភសេពសន្ថវៈ ឬបៀតបៀនកេរ្តិ៍ខ្មាស់អាចជាឧបសគ្គដល់ការលូតលាស់ជាធម្មតារបស់កុមារ ដែលអាចបណ្តាលអោយការលូតលាស់របស់កុមារមានការយឺតយ៉ាវ ឬខុសពីប្រក្រតិ និងអាចរងគ្រោះពីការឆ្លងជំងឺដ៏សាហាវដូចជាអេដស៍ជាដើម ។ ប្រការដែលមានកុមាររងគ្រោះជាច្រើនអាយុក្រោម ១០ ឆ្នាំ ជាការដាស់អារម្មណ៍ដល់មនុស្សគ្រប់រូប ។ ទោះបីជាអាយុជនរងគ្រោះប៉ុន្មានក៏ដោយក៏ការបំបាត់ចោលកត្តានានាដែលនាំអោយជនល្មើសរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ជាបញ្ហាសំខាន់ជាទីបំផុត ។ ជនល្មើសមិនត្រូវជឿថា គេអាចគេចផុតពីការផ្តន្ទាទោសបានទេ ។ អង្គការលីកាដូសង្ឃឹមថា ចៅក្រម និងមន្ត្រីអនុវត្តច្បាប់នានាទទួលស្គាល់ថា រាល់ករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់មិនទាក់ទងទៅអត្តសញ្ញាណ និងអត្តចរិតរបស់ជនល្មើស ឬជនរងគ្រោះទេសំខាន់បំផុតនោះ គឺតំរូវអោយមានការអនុវត្តន៍ត្រឹមត្រូវនៅតុលាការ ។

វាត្រូវបានគេដឹងឮគ្រប់មជ្ឈដ្ឋានទៅហើយ ថាតុលាការនៅកម្ពុជាអនុវត្តតួនាទីរបស់ខ្លួនក្រោមកំរិតពិចារណាជាច្រើន។ ទោះជាយ៉ាងនេះក្តី ការប្រព្រឹត្តនៃបទឧក្រិដ្ឋផ្លូវភេទក្នុងប្រព័ន្ធយុត្តិធមិអាចត្រូវតែលំអរ ឬធ្វើអោយប្រសើរឡើង ដើម្បីជាផលប្រយោជន៍ដល់សង្គមកម្ពុជាទូទៅ និងជាពិសេសចំពោះជនរងគ្រោះដោយករណីរំលោភសេពសន្ថវៈ។

ឆ្លងកាត់តាមបទពិសោធន៏កន្លងមក ប្រសិទ្ធិភាពនៃការស៊ើបអង្កេត និងដំណើរការសវនាក្តី តុលាការកម្ពុជាអាចដើរតួនាទីយ៉ាងសារៈសំខាន់ក្នុងកិច្ចការពារបទល្មើសរំលោភសេពសន្ថវៈ និងអំពើបៀតបៀនកេរ្តិ៍ខ្មាស់ ។ ការដែលប្រកាន់យកការវិនិច្ឆ័យទោសអោយបានធ្ងន់ធ្ងរ ចំពោះបទល្មើសរំលោភសេពសន្ថវៈនឹងអាចផ្តល់នូវប្រសិទ្ធិភាពទូទៅក្នុងការបង្កើនជំនឿសាធារណៈមកលើប្រព័ន្ធយុត្តិធម៌ ដោយឡែកនឹងជួយលើកទឹកចិត្តជនរងគ្រោះខាងផ្លូវភេទអោយហ៊ានរាយការណ៍ និងដាក់ពាក្យបណ្តឹង ដើម្បីស្វែងរកយុត្តិធម៏តាមផ្លូវច្បាប់ចំពោះបទល្មើសទាំងនោះចំពោះពួកគេ ។

**<u>សូមទំនាក់ទំនង :</u>**


លោកស្រីវេជ្ជ. **ពុង ឈីវកេក** ប្រធានអង្គការលីកាដូ

អាសយដ្ឋាន : #103 ផ្លូវ ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន ភ្នំពេញ

ទូរស័ព្ទលេខ: (855) 23 360 965 / 364 901

ទូរសារលេខ : (855) 23 360 965 / 217 626

E-mail: licadho@camnet.com.kh

Website: http://www.licadho.org/